FIRST FINANCE

# ដៃគូដំណោះស្រាយ ហិរញ្ញវត្ថុផ្នែក លំនៅដ្ឋាន

របាយការណ៍ប្រចាំឆ្នាំ ២០២២




កម្ចីទិញផ្ទះ
100,000
ដុល្លារ
រយៈពេលរហូតដល់
២០ឆ្នាំ
ជ្រើសរើសម៉ូតផ្ទះ
ដែលលោកអ្នកស្រឡាញ់
រៀងថវិកា សូមពិភាក្សាជាមួយ ហ្វឹស ហ្វាយនែន
093 666 635
firstfinance
www.firstfinance.com.kh
FIRST FINANCE

# តារាងមាតិកា

០៤. សមិទ្ធផលរបស់យើង

០៨. ផលិតផល និងដំណោះស្រាយ

១០. សារពីប្រធានក្រុមប្រឹក្សាភិបាល

១២. សារពីប្រធាននាយកប្រតិបត្តិ

១៦. អំពី ហ្វីស ហ្វាយនែន

១៨. សាវតានៃដំណើរវិវឌ្ឍន៍

២០. នាមស្ថាប័នផ្តល់ហិរញ្ញប្បទាន

២១. រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន

២២. ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង

២៦. ទិដ្ឋភាពទូទៅនៃអាជីវកម្ម

៣០. ទិដ្ឋភាពទូទៅនៃសមិទ្ធិផលសង្គម និងបរិស្ថាន

៣៣. ការទទួលស្គាល់ពីការអនុវត្តន៍គោលការណ៍ការពារអតិថិជន

៣៤. របាយការណ៍របស់សវនករឯករាជ្យ

៣៦. របាយការណ៍ហិរញ្ញវត្ថុ

*តួលេខក្នុងរបាយការណ៍នេះ គឺរបស់ ហ្វីស ហ្វាយនែន សម្រាប់ការិយបរិច្ឆេទ ០១ មករា ២០២២ ដល់ ៣១ ធ្នូ ២០២២*

# សមិទ្ធផលរបស់យើង

ហ្វឹស ហ្វាយនែន ជឿជាក់ថាការជួយអោយមនុស្សមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន គឺជាកត្តាសំខាន់ក្នុងការជួយអោយពួកគាត់មានជីវិតប្រសើរឡើង ។ ស្ថេរភាពនៃការដែលមានផ្ទះផ្ទាល់ខ្លួន អាចជួយអោយគ្រួសារបានចំណាយពេលវេលា និងថាមពលទៅលើកត្តាផ្សេងទៀតដែលសំខាន់សម្រាប់ជីវិត ។ ក្មេងៗអាចចំណាយពេលសិក្សារៀនសូត្រ ចំណែកឯស្ត្រីអាចចាប់យករបរផ្សេងៗ ឬបម្រើការងារ ។ ទាំងនេះអាចជួយអោយទំនាក់ទំនងរវាងអ្នកជិតខាង និងសហគមន៍ក៏កាន់តែរឹងមាំ ។ ទំនាក់ទំនងដែលរឹងមាំនេះហើយ ដែលនាំមកនូវការគោរពរវាងគ្នានៅក្នុងគ្រួសារ ។ ការដែលមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអត្តសញ្ញាណបុគ្គល ។ សុវត្ថិភាព និងសន្តិសុខរបស់គ្រួសារនឹងកាន់តែកើនឡើង នៅពេលដែលពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ។

## ភាគរយអតិថិជនតាមភេទ



៦៤%

៣៦%

## ចំនួនអតិថិជនសកម្មសរុប



២.១៧៩

## ភាគរយអតិថិជនតាមទំហំចំណូលប្រចាំខែ

| | |
|---|---|
| ចំណូលទាបជាង ៣០០ ដុល្លារ | ១៧% |
| ចំណូលនៅចន្លោះ ៣០០-៧០០ ដុល្លារ | ៤៥% |
| ចំណូលចន្លោះ ៧០០-១.០០០ ដុល្លារ | ១៥% |
| ចំណូលខ្ពស់ជាង ១.០០០ ដុល្លារ | ២៣% |

## ភាគរយអតិថិជន តាមប្រភពចំណូល




## ផលបត្រឥណទាន តាមប្រវត្តិអតិថិជន



# ផលបត្រឥណទាន តាមប្រភេទផលិតផលឥណទាន

**កម្ចីទិញផ្ទះ**

**៣៨,៣%** នៃចំនួនផលបត្រឥណទានសរុប

**៥៧៧** ចំនួនប្រាក់កម្ចីសកម្ម

---

**៦៨៧** ចំនួនប្រាក់កម្ចីសកម្ម

**២០,៦%** នៃចំនួនផលបត្រឥណទានសរុប

**កម្ចីសាងសង់ ជួសជុលផ្ទះ**

---

**កម្ចីទិញដី លំនៅដ្ឋាន**

**២៥,៥%** នៃចំនួនផលបត្រឥណទានសរុប

**៨៣០** ចំនួនប្រាក់កម្ចីសកម្ម

---

**៦០៩** ចំនួនប្រាក់កម្ចីសកម្ម

**១៥,៦%** នៃចំនួនផលបត្រឥណទានសរុប

**កម្ចីអចលនទ្រព្យធានា**

# តំបន់ប្រតិបត្តិការ




- តំបន់ប្រតិបត្តិការដែលមានការិយាល័យ
- តំបន់ប្រតិបត្តិការដែលមិនមានការិយាល័យ
- តំបន់សក្ដានុពលក្នុងការពង្រីកប្រតិបត្តិការ

**៣៥.៨៤ លាន**
ផលបត្រឥណទាន

**១១**
ការិយាល័យ

**១៩៤ នាក់**
បុគ្គលិក

# ផលិតផល និងដំណោះស្រាយ

## កម្ចីទិញផ្ទះ និងសង់ផ្ទះ

ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីយកទៅទិញផ្ទះ ឬសាងសង់ផ្ទះនៅលើដីដែលមានស្រាប់ ។

## កម្ចីកែលម្អផ្ទះ

ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីយកទៅកែលម្អ និងជួសជុលផ្ទះ ។

## កម្ចីទិញដីលំនៅដ្ឋាន

ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីយកទៅទិញដីលំនៅដ្ឋាន ដើម្បីទុកសាងសង់ផ្ទះ ។

## កម្ចីអចលនទ្រព្យធានា

ជាប្រភេទកម្ចីរយៈពេលវែង ប្រើប្រាស់ដើម្បីកែប្រែគុណភាពជីវិតតាមរយៈការទិញសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ។

## កម្ចីអាជីវកម្ម

ជាប្រភេទកម្ចីរយៈពេលវែង ដែលប្រើប្រាស់អចលនទ្រព្យបញ្ចាំ ដើម្បីយកធ្វើជាដើមទុនបង្កើត ឬពង្រីកអាជីវកម្ម ។



“អរគុណ ហ្វីស ហ្វាយនែន ដែលបានផ្តល់ប្រាក់កម្ចីកែលម្អផ្ទះសម្រាប់គ្រួសារខ្ញុំ

# ជួយដល់ស្ត្រី និងកុមារ បានរស់នៅប្រកបដោយសុវត្ថិភាព និងផាសុខភាព

ក្នុងតួនាទីជាស្ត្រីមេគ្រួសារ អ្នកស្រី គិន ស៊ីនួន បានខិតខំធ្វើការដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ និងផ្តល់នូវលំនៅដ្ឋានដ៏សមរម្យមួយទៅដល់កូនស្រីអាយុ ៨ឆ្នាំ និងឪពុកម្តាយចាស់របស់គាត់ បន្ទាប់ពីគាត់បានលែងលះគ្នាជាមួយស្វាមី ។ អ្នកស្រីលើកឡើងថា៖ " ជាស្ត្រីមេម៉ាយ វាជាការលំបាកដែលត្រូវធ្វើការម្នាក់ឯងដើម្បីផ្គត់ផ្គង់គ្រួសារ និងត្រូវសន្សំដើម្បីសង់ផ្ទះដ៏សមរម្យមួយ " ។

ស្ថានភាពផ្ទះរបស់អ្នកស្រីគឺមិនទាន់មានសុវត្ថិភាព និងផាសុខភាពគ្រប់គ្រាន់នៅឡើយសម្រាប់កូនស្រី និងឪពុកម្តាយជរា ។ ដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់ផ្ទះដែលមានសុវត្ថិភាព និងផាសុខភាពទៅដល់កូនស្រី និងឪពុកម្តាយជរា អ្នកស្រីក៏សម្រេចចិត្តពង្រីកផ្ទះ និងសង់បន្ទប់ថ្មីបន្ថែម ដើម្បីផ្តល់ភាពងាយស្រួលជាពិសេសសម្រាប់កូនស្រី និងឪពុកម្តាយជរា ។

ប្រាក់ចំណូល ៥០០ ដុល្លារ ក្នុងមួយខែ ដែលបានមកពីការលក់ចាប់ហួយ និងបោកអ៊ុត អាចឱ្យអ្នកស្រីស្នើកម្ចីកែលម្អផ្ទះ ពី ហ្វីស ហ្វាយនែន ចំនួន ១០.០០០ ដុល្លារ មានរយៈពេលសរុប ៦០ខែ ។ អ្នកស្រី ស៊ីនួន ពេញចិត្តនិងរយៈពេល និងសេវាកម្មរបស់ ហ្វីស ហ្វាយនែន អ្នកស្រីបន្ថែមថា៖ "អរគុណ ហ្វីស ហ្វាយនែន ដែលបានផ្តល់ប្រាក់កម្ចីកែលម្អផ្ទះសម្រាប់គ្រួសារខ្ញុំ។"



# សារពីប្រធានក្រុមប្រឹក្សាភិបាល

“

បង្កើតអនាគតដ៏ភ្លឺស្វាងមួយសម្រាប់ក្រុមគ្រួសារដែលត្រូវការវិនិយោគទុនលំនៅដ្ឋានខ្នាតតូច ។ ប្រតិបត្តិការអាជីវកម្មយើងខ្ញុំ នៅតែដំណើរការបានយ៉ាងល្អ បើទោះបីស្ថិតក្នុងឆ្នាំដែលប្រឈម និងកំឡុងពេលផ្លាស់ប្តូរភាគទុនិកក៏ដោយ។ យើងខ្ញុំនឹងបន្តផ្តោតលើផលប៉ះពាល់ផ្នែកសង្គម តាមរយៈការពង្រីកវិសាលភាពអាជីវកម្ម ដោយផ្តល់សេវាកម្ចីទៅកាន់គ្រួសារដែលមានចំណូលទាបឱ្យបានកាន់តែច្រើន។

**HANCO Halbertsma**
ប្រធានក្រុមប្រឹក្សាភិបាល

**ជម្រាបសួរមិត្តភក្តិ ហ្វឺស ហ្វាយនែន ទាំងអស់!**

២០២២ គឺជាឆ្នាំដ៏ពិសេសមួយសម្រាប់ ហ្វឺស ហ្វាយនែន ។ ក្រោយពេលវិបត្តិកូវីដជាសកលបានមកដល់ចំណុចបញ្ចប់ ប្រទេសកម្ពុជាក៏ដូចជាអតិថិជនរបស់ ហ្វឺស ហ្វាយនែន បានទទួលការសម្រាលបន្ទុកមួយផ្នែកធំ ពីព្រោះវិបត្តិនេះបានធ្វើអោយមានផលប៉ះពាល់ទៅដល់ជីវិតក្រុមគ្រួសារ និងអាជីវកម្មរបស់អតិថិជនរបស់យើងខ្ញុំ ។ ក្នុងកំឡុងពេលនេះដែរ ភាគទុនិកចាស់ដែលបានកាន់កាប់ ហ្វឺស ហ្វាយនែន ជាច្រើនឆ្នាំកន្លងមក បានសម្រេចចិត្តផ្ទេរភាគហ៊ុន ១០០% របស់ខ្លួនទៅកាន់ភាគទុនិកថ្មី ដើម្បីគ្រប់គ្រងបន្តនៅក្នុងខែកក្កដា ឆ្នាំ ២០២២ ។

បើទោះបីអ្នកគ្រប់គ្រងមុន ក្រោមការជួយជ្រោមជ្រែងពីភាគទុនិក បានបង្កើតគ្រឹះអាជីវកម្មផ្តល់សេវាហិរញ្ញវត្ថុ ដែលរឹងមាំមួយហើយក្តី ក៏ប៉ុន្តែទំហំអាជីវកម្មហាក់នៅតូចពេកសម្រាប់ការបោះជំហ៊ានវែងក្នុងដំណើរឆ្ពោះទៅកាន់ស្ថាប័នមួយដែលមានទំហំធំ ។ ភាគទុនិកថ្មីបានបង្កើនដើមទុនបន្ថែម ដែលវាបានផ្តល់នូវជំហរហិរញ្ញវត្ថុដ៏រឹងមាំមួយ និងបានតែងតាំងគណៈគ្រប់គ្រងថ្មី ដែលពោរពេញទៅដោយចំណេះដឹង និងបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ ហ្វឺស ហ្វាយនែន បានត្រៀមជាស្រេចសម្រាប់សន្ទុះនៃការរីកចម្រើនឆ្ពោះទៅរកស្ថាប័នដ៏ធំមួយ ដែលអាចផ្តល់សេវាឥណទានលំនៅដ្ឋានខ្នាតតូចទៅកាន់ក្រុមគ្រួសារកាន់តែច្រើនជាងមុន ។

នៅពេលចាប់ផ្តើមការងារនៅ ហ្វឺស ហ្វាយនែន ដើម្បីធ្វើឱ្យប្រតិបត្តិការអាជីវកម្មមានភាពប្រសើរឡើង គណៈគ្រប់គ្រងថ្មីបានធ្វើការត្រួតពិនិត្យលម្អិតលើប្រតិបត្តិការ និងអាជីវកម្ម ហើយបានដាក់ចេញនូវគម្រោងជាច្រើន ដូចជាការធ្វើឱ្យប្រសើរឡើងលើដំណើរការគ្រប់គ្រងហានិភ័យឥណទាន ការទាក់ទាញនូវប្រភពទុនធំៗ ការធ្វើឱ្យប្រសើរឡើងលើការគ្រប់គ្រងផ្ទៃក្នុង ការបង្កើនសមត្ថភាពបុគ្គលិក និងការពង្រីកវិសាលភាពតំបន់ប្រតិបត្តិការ ។

ក្នុងដំណាក់កាលឆមាសទី ២ នៃឆ្នាំ ២០២២ គណៈគ្រប់គ្រងថ្មីបានសម្រេចនូវកិច្ចការមួយចំនួនដូចជា៖ (១) ធ្វើការកែប្រែឱ្យប្រសើរឡើងទៅលើគោលនយោបាយ និងគោលការណ៍ចាំបាច់មួយចំនួន (២) ប្តូរទីតាំងការិយាល័យកណ្តាលថ្មី (៣) បង្កើតសាខាថ្មីៗ និងបង្កើនបុគ្គលិកនៅតាមសាខា (៤) បង្កើនចំនួនអតិថជន ដោយផ្តោតការយកចិត្តទុកដាក់លើហានិភ័យនៅតាមសាខា (៥) រៀបចំបម្រុងប្រភពទុនថ្មីៗបន្ថែម ដើម្បីត្រៀមជាស្រេចក្នុងការពង្រីកអាជីវកម្មក្នុងពេលដ៏ខ្លីខាងមុខ ។

នៅក្នុងឆ្នាំ ២០២២ នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន បានបង្កើនផលបត្រឥណទានទៅដល់ ៣៥,៨៤ លានដុល្លារ កើនប្រមាណ ១៧% ដោយបានផ្តល់សេវាកម្មីទៅកាន់អតិថិជនថ្មីប្រមាណជិត ៨០០ គ្រួសារ បានធ្វើការជ្រើសមន្ត្រីឥណទានថ្មីជាង ១០០រូបនិងបង្កើតសាខាចំនួនពីរបន្ថែមទៀត។នៅក្នុងដើមត្រីមាសទី ១ ក្នុងឆ្នាំ ២០២៣ ការរីកចម្រើននៅតែបន្តសន្ទុះទៅមុខ ព្រមជាមួយវិសាលភាពប្រតិបត្តិការកាន់តែធំជាងមុន ។

ភាគទុនិក និងគណៈគ្រប់គ្រងថ្មី នៅតែរក្សាជំហរបន្តផ្តល់សេវាកម្ចីលំនៅដ្ឋានខ្នាតតូច រយៈពេលវែងទៅកាន់ក្រុមគ្រួសារដែលមានចំណូលទាប និងមធ្យម ដោយ ៦២% នៃអតិថិជនទាំងអស់មានចំណូលប្រចាំខែក្រោម ៧០០ដុល្លារ ។ តាមរយៈសេវាកម្ចីដែលបានផ្តល់ជូន អាចឱ្យពួកគាត់មានលទ្ធភាពទទួលបានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន និងមានជីវភាពរស់នៅសមរម្យប្រកបដោយស្ថេរភាព ។ អតិថិជនចំនួន ៦៣% គឺជាក្រុមគ្រួសារដែលទើបតែមានផ្ទះលើកដំបូងជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ ជាងនេះទៅទៀត យើងខ្ញុំបានផ្តោតទៅលើការផ្តល់សេវាកម្ចីកែលម្អលំនៅដ្ឋានទៅកាន់អតិថិជនចាស់ និងថ្មី ដែលភាគច្រើនគឺប្រើប្រាស់ទាក់ទងទៅនឹងទឹកស្អាត និងអនាម័យ ដែលវាបានជួយគាំទ្រទៅដល់អាជីវកម្មខ្នាតតូចប្រចាំគ្រួសាររបស់ពួកគេផងដែរ ។ យើងខ្ញុំមានទំនុកចិត្តថា យុទ្ធសាស្ត្រឆ្ពោះទៅរកភាពរីកចម្រើនរបស់យើងខ្ញុំ នឹងទទួលបាននូវភាពជោគជ័យ ដែលនឹងផ្តល់នូវផលប៉ះពាល់ជាវិជ្ជមានកាន់តែធំជាងមុនទៅដល់សង្គមគ្រួសារដែលមានចំណូលទាប និងមធ្យម នៅក្នុងឆ្នាំ ២០២៣ នេះ ។

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅកាន់អតិថិជន បុគ្គលិកគ្រប់ជាន់ថ្នាក់ ម្ចាស់បំណុល ដៃគូរអាជីវកម្ម ព្រមទាំងភាគទុនិកចាស់ និងថ្មីទាំងអស់ ដែលបានចូលរួមចំណែកដល់ភាពជោគជ័យរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ភីអិលស៊ី ក្នុងឆ្នាំ ២០២២ ។

សម្រាប់ឆ្នាំ ២០២៣ ខាងមុខនេះ ភាគទុនិក ព្រមទាំងក្រុមប្រឹក្សាភិបាលទាំងអស់ សូមសំដែងនូវមោទកភាពខ្ពស់ ចំពោះការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ស្ថាប័នផ្តល់ប្រាក់កម្ចី ព្រមទាំងភាគីពាក់ពន្ធ័ជាច្រើនទៀត ដែលស្ថិតនៅក្នុងវិស័យលំនៅដ្ឋានដែលមានតម្លៃសមរម្យនេះ ។




**HANCO Halbertsma**
ប្រធានក្រុមប្រឹក្សាភិបាល



# សារពីប្រធាន នាយកប្រតិបត្តិ

"យើងបានបញ្ចប់កំណែទម្រង់ប្រកបដោយជោគជ័យដែលបង្ហាញឡើងតាមរយៈលទ្ធផលប្រកបដោយឧត្តមភាព ព្រមជាមួយការបង្កើននូវទំនុកចិត្តពីម្ចាស់បំណុល និយ័តករ និងភាគីដែលពាក់ពន្ធ័ដ៏ទៃផ្សេងទៀត ។ ជាងនេះទៅទៀត យើងបានពង្រីកវិសាលភាពនៃការផ្តល់សេវាប្រាក់កម្ចីសំរាប់លំនៅដ្ឋានខ្នាតតូចទៅកាន់គ្រួសារដែលមានចំណូលទាប និងមធ្យមនៅក្នុងប្រទេសកម្ពុជាបានកាន់តែច្រើន។

**លោក ស៊ឹម សេនាជាតិ**
ប្រធាននាយកប្រតិបត្តិ

ចាប់តាំងពីពេល ដែលខ្ញុំបាទបានមកកាន់តំណែង ជាប្រធាននាយកប្រតិបត្តិ នៅក្នុងខែកក្កដា ឆ្នាំ ២០២២ មក ខ្ញុំបានរៀបចំនូវផែនការ និងយុទ្ធសាស្ត្រដើម្បីឱ្យសកម្មភាពអាជីវកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន មានភាពប្រសើរឡើងឆ្ពោះទៅមុខប្រកបដោយស្ថេរភាព ។ តាមរយៈការអនុវត្តន៍នូវផែនការ និងយុទ្ធសាស្ត្រ ព្រមជាមួយដំណើរឆ្ពោះទៅរកការសម្រេចបាននូវផែនការទាំងនោះ នឹងធ្វើឱ្យ ហ្វីស ហ្វាយនែន ក្លាយជាស្ថាប័នលេចធ្លោរមួយនៅក្នុងវិស័យហិរញ្ញវត្ថុ ។ ដោយរាប់ចាប់ពីថ្ងៃទីមួយមក យើងខ្ញុំបានចាប់ផ្តើមកែប្រែ ហ្វីស ហ្វាយនែន ឱ្យក្លាយទៅជាស្ថាប័នមួយ ដែលមានអភិបាលកិច្ចសាជីវកម្មល្អ មានវប្បធម៌ក្នុងការអនុវត្តន៍ការងារល្អ និងភាពម៉ឺងម៉ាត់លើវិន័យឥណទាន មានភាពហ្មត់ចត់លើការគ្រប់គ្រងផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ ជាស្ថាប័នដែលមានគុណភាពឥណទានល្អ ហានិភ័យទាប ផលិតភាពខ្ពស់ ប្រសិទ្ធភាព និងស្ថេរភាពហិរញ្ញវត្ថុខ្ពស់ ។

អ្វីដែលសំខាន់ ហ្វីស ហ្វាយនែន នឹងធ្វើការពង្រីកខ្លួន ព្រមទាំងបង្កើនប្រសិទ្ធភាព ក្នុងការតាំងនូវជំហរដ៏រឹងមាំមួយ ដើម្បីឆ្លងកាត់នូវដំណាក់កាលដែលលំបាកនេះ ។ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់បញ្ហាប្រឈម និងដើម្បីពង្រឹងសមិទ្ធផលហិរញ្ញវត្ថុឲ្យបានកាន់តែរឹងមាំនាឆ្នាំខាងមុខ តម្រូវឱ្យយើងខ្ញុំអនុវត្តនូវយុទ្ធសាស្ត្រដូចតទៅនេះ (១). រក្សានូវទស្សនៈវិស័យ និងបេសកកម្មបច្ចុប្បន្ន ក្នុងការបន្តផ្តល់និងពង្រីកនូវសេវាកម្ចីលំនៅដ្ឋានខ្នាតតូច ទៅកាន់ក្រុមគ្រួសារដែលមានចំណូលទាប និងមធ្យមនៅក្នុងប្រទេសកម្ពុជា (២). បង្កើនដើមទុនចុះបញ្ជីទៅដល់ ១៥ លានដុល្លារសហរដ្ឋអាមេរិក ក្នុងគោលបំណងបង្កើននូវទំនុកចិត្តពីសាធារណជន និងដៃគូនានា (៣). ខ្ចីអនុបំណុលដើម្បីបង្កើនអនុបាតសាធនភាព ហើយប្រើប្រាស់សម្រាប់ផ្តល់ឥណទាន និងស្វែងរកទុនបន្ថែមពីម្ចាស់បំណុលថ្មី និងមានស្រាប់ (៤). បង្កើនគុណភាពផលបត្រឥណទាន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ នីតិវិធី និងដំណើរការ (៥). ធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយធនធានមនុស្សដើម្បីរក្សានិងទាក់ទាញបុគ្គលិកដែលល្អ និងមានគុណសម្បត្តិគ្រប់គ្រាន់ (៦). ធ្វើអោយប្រសើរឡើង/អភិវឌ្ឍគោលនយោបាយ និងនីតិវិធីមួយចំនួន ដូចជា អភិបាលកិច្ចសាជីវកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងហានិភ័យ ពង្រឹងលើការត្រួតពិនិត្យផ្ទៃក្នុង និងបង្កើនការយល់ដឹងលើការគ្រប់គ្រងហានិភ័យ (៧). បង្កើនប្រសិទ្ធភាពការងារតាមរយៈការបន្ថយចំណាយធៀបនឹងចំណូល ដោយធ្វើការបង្កើនផលិតភាពការងាររបស់មន្ត្រីឥណទាន និងបង្កើនផលិតភាពការងារសាខាទាំងអស់ (៨). ពង្រឹងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធស្នូលធនាគារ (៩). បន្តធ្វើអោយប្រសើរឡើង និងពង្រឹងបន្ថែមទៅលើកិច្ចការពារអតិថិជន ដើម្បីទទួលបានវិញ្ញាបនបត្រការពារអតិថិជន និងចូលរួមគាំទ្រដល់សកម្មភាពទទួលខុសត្រូវផ្នែកសង្គមនានាផងដែរ ។

លទ្ធផលនៅក្នុងឆ្នាំ ២០២២ បានបង្ហាញយ៉ាងច្បាស់ពីប្រសិទ្ធភាពរបស់យុទ្ធសាស្ត្រទាំងនោះ ក្នុងការឆ្លើយតបទៅនឹងកំណែទម្រង់និងបញ្ហាប្រឈមនានា ។ វាបានបង្ហាញឱ្យឃើញថា ហ្វីស ហ្វាយនែន នឹងបន្តនាំយកនូវភាពខ្លាំង និងសមត្ថភាពដែលលេចធ្លោ ទៅកាន់ឆ្នាំខាងមុខៗទៀត ។ យើងខ្ញុំកំពុង នឹងបន្តប្រែក្លាយ ហ្វីស ហ្វាយនែន ទៅជាស្ថាប័នដែលមានកម្ចីមិនដំណើរការទាប ផលិតភាពបុគ្គលិកខ្ពស់ មានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងចំណាយ មានទំនាក់ទំនងល្អជាមួយអតិថិជន គ្រប់គ្រងដើមទុន និងហានិភ័យប្រកបដោយភាពវៃឆ្លាត និងជាកន្លែងដែលបុគ្គលិកគ្រប់គ្នាចង់ធ្វើការជាមួយ ។ យើងខ្ញុំ នឹងបន្តបង្កើតវប្បធម៌ដែលមានភាពរឹងមាំ សុច្ចរិតភាព និងប្រកាន់ខ្ជាប់នូវវិជ្ជាជីវៈនៅគ្រប់សកម្មភាពអាជីវកម្មរបស់យើង ។ យើងខ្ញុំមានមោទនភាពចំពោះសមិទ្ធផលរបស់យើង ។ តាមរយៈប្រវត្តិការងារជោគជ័យរបស់យើង រួមជាមួយលក្ខណៈពិសេសខុសប្លែកពីគូប្រកួតប្រជែងនឹងធ្វើអោយយើងខ្ញុំបង្កើតបាននូវគុណតម្លៃរយៈពេលវែងជូនដល់ម្ចាស់បំណុល និងភាគីដែលពាក់ព័ន្ធនានា។

ហ្វីស ហ្វាយនែន ចាប់ផ្តើមរីកលូតលាស់ ព្រមជាមួយសមិទ្ធផលហិរញ្ញវត្ថុមានភាពប្រសើរឡើង ក្នុងឆ្នាំ ២០២២ ។

**ទ្រព្យសកម្ម**

**$៤៧,៦៨លាន**

↑ ៤៤,៦២%

**ផលបត្រឥណទាន**

**$៣៥,៨៤លាន**

↑ ១៧,៥០%

**ប្រាក់ចំណេញសុទ្ធ**

**$០,៣៣លាន**

↑ ២៧៣,៩៦%

## ( ត ) សាររបស់ប្រធាននាយកប្រតិបត្តិ

| កម្ចីមិនដំណើរការ | ផលលើមូលធន (ROE) | ផលលើទ្រព្យសកម្ម (ROA) |
| --- | --- | --- |
| ២,៩៨% | ២,៨៩% | ០,៨២% |

### ការអនុវត្តន៍យុទ្ធសាស្ត្រដែលមានលក្ខណៈច្បាស់លាស់ និងមិនលំអៀង

យុទ្ធសាស្ត្ររបស់យើងខ្ញុំ គឺជាយុទ្ធសាស្ត្រដែលមានលក្ខណៈច្បាស់លាស់ និងមិនលំអៀង ។ យើងខ្ញុំប្តេជ្ញាផ្តល់នូវការរីកចំរើនមួយប្រកបដោយគុណភាពខ្ពស់ និងមានគុណតម្លៃរយៈពេលវែងសម្រាប់ម្ចាស់បំណុល និងភាគទុនិកទាំងអស់។ យុទ្ធសាស្ត្រនេះក៏នឹងចូលរួមបង្កើនគុណភាព ទ្រព្យសកម្មឲ្យមានកម្រិតខ្ពស់ និងប្រាក់ចំណេញដែលពោរពេញដោយនិរន្តភាពផងដែរ ។ យើងខ្ញុំនឹងបន្តចាប់យកឱកាស ដែលស្របទៅនឹងការយល់ឃើញរបស់យើងខ្ញុំទាក់ទងនិន្នាការទីផ្សារ ក៏ដូចជាពង្រឹងភាពខ្លាំងរបស់យើងខ្ញុំ រួមជាមួយការផ្តល់នូវគុណតម្លៃដ៏រឹងមាំ ទៅកាន់ភាគីដែលពាក់ព័ន្ធ ។

### ធានាឱ្យបាននូវនិរន្តភាពប្រត្តិបត្តិការ និងដំណើរឆ្ពោះទៅមុខជានិច្ច

កិច្ចខិតខំប្រឹងប្រែងរបស់យើងខ្ញុំ គឺធ្វើឱ្យប្រតិបត្តិការមាននិរន្តភាព និងមានភាពប្រសើរឡើង បង្កើតនូវភាពជឿជាក់ ទំនុកចិត្ត មានក្រមសីលធម៌ និងវប្បធម៌រឹងមាំ ធ្វើដូច្នេះទើបអាចធ្វើឱ្យយើងខ្ញុំមានការប្រុងប្រយ័ត្ន និងមានដំណើរប្រកបដោយនិរន្តភាពឆ្ពោះទៅរកផែនការ និងយុទ្ធសាស្ត្រដែលធ្វើឱ្យអាជីវកម្មមានភាពប្រសើរឡើង ។

### ការដឹកនាំប្រកបទំនុកចិត្ត

យើងបានមើលឃើញពីឱកាស បើទោះបីមានបញ្ហាប្រឈមជាច្រើនបានធ្វើឱ្យប៉ះពាល់ ទៅដល់ប្រតិបត្តិការអាជីវកម្មរបស់យើងខ្ញុំមានដូចជាកំណើនសេដ្ឋកិច្ចមានភាពយឺតយ៉ាវ ការកើនឡើងនូវអត្រាការប្រាក់ និងអតិផរណាឡើងខ្ពស់ ការផ្លាស់ប្តូរលើបទបញ្ញត្តិ បម្រែបម្រួលទីផ្សារ និងការកើនឡើងនៃការប្រកួតប្រជែងជាដើម ។ យើងខ្ញុំបាននឹងប្តេជ្ញាចិត្តអនុវត្តនូវយុទ្ធសាស្ត្រដែលសមស្រប ពង្រឹងវប្បធម៌ និងបង្កើនសមត្ថភាពបុគ្គលិក ដើម្បីឆ្ពោះទៅកាន់ភាពរីកចម្រើន និងឆ្លៀតចាប់យកឱកាសក្នុងបរិបទទីផ្សារមានការផ្លាស់ប្តូរនេះ។ ក្នុងមួយរយៈពេលកន្លងមកនេះ បានបង្ហាញឱ្យឃើញថាយុទ្ធសាស្ត្ររបស់យើងខ្ញុំ បានបំពេញមុខងារយ៉ាងល្អ ។ យើងខ្ញុំកាន់តែមានទំនុកចិត្តច្រើនជាងមុន ដែលបានជ្រើសរើសនូវយុទ្ធសាស្ត្រសមស្រប និងធនធានមនុស្សត្រឹមត្រូវ ដើម្បីទប់ទល់នឹងបញ្ហាប្រឈមនៅខាងមុខ ។ យើងខ្ញុំនៅតែបន្តទទួលខុសត្រូវ លើការរីកចម្រើនប្រកបដោយនិរន្តភាព និងខិតខំប្រឹងប្រែងក្នុងការនាំយកអតិថិជន និងភាគទុនិកដើម្បី រួមដំណើរជាមួយយើងខ្ញុំ ឆ្លងកាត់ពេលវេលាលំបាកមួយនេះ ឆ្ពោះទៅរកអនាគតមួយដែលគាប់ប្រសើរជាមួយគ្នា ។

តាមរយៈការអនុវត្តន៍យុទ្ធសាស្ត្រអោយបានត្រឹមត្រូវ និងបង្កើតឱ្យមានវឌ្ឍនភាពសមស្រប ដោយផ្តោតទៅលើកិច្ចការជាអាទិភាពនោះ ហ្វឺស ហ្វាយនែន នឹងមានគោលជំហរប្រសើរមួយក្នុងការសម្រេចសមិទ្ធផលគោលដៅរយៈពេលមធ្យម ដែលនឹងបង្កើតនូវគុណតម្លៃរយៈពេលវែងជូនទៅដល់ភាគីដែលពាក់ព័ន្ធ ។ យើងខ្ញុំ នៅតែបន្តរក្សាកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបាននូវឧត្តមភាព តាមរយៈកិច្ចសហប្រតិបត្តិការ ការប្តេជ្ញាចិត្ត និងតម្លាភាពនៅគ្រប់កិច្ចការរបស់យើង ។

ជួសមុខឱ្យគណៈគ្រប់គ្រងរបស់ ហ្វឺស ហ្វាយនែន ខ្ញុំបាទសូមថ្លែងអំណរគុណដល់ថ្នាក់គ្រប់គ្រងគ្រប់លំដាប់ថ្នាក់ និងបុគ្គលិកទាំងអស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារ អរគុណដល់ក្រុមប្រឹក្សាភិបាល សម្រាប់ការគាំទ្រ និងជំបូន្មាន អរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា និយ័តករ ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ដែលតែងតែគាំទ្រ និងបន្តគាំទ្រដល់ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ។

**លោក ស៊ឹម សេនាជាតិ**
ប្រធាននាយកប្រតិបត្តិ



"ខ្ញុំពិតជាអរគុណខ្លាំងណាស់ដល់ ហ្វីស ហ្វាយនែន ដែលបានផ្តល់កម្ចីដើម្បីបង្ហើយផ្ទះ លើសពីនេះក៏អាចពង្រីកអាជីវកម្មផងដែរ ពីព្រោះខ្ញុំមានទីតាំងទូលាយអាចប្រកបរបរបាន

# បំពេញក្តីសុបិន្តចង់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន

អ្នកស្រី ប៊ុនរ័ត្ន បានរៀបអាពាហ៍ពិពាហ៍ជាមួយលោក វុទ្ធី និងបានរស់នៅជាមួយឪពុកម្តាយអស់រយៈពេលជាង ១០ឆ្នាំ នៅក្នុងខេត្តបាត់ដំបង ។ ពួកគាត់មានកូនគួរឱ្យស្រឡាញ់ពីរនាក់ កូនស្រីច្បងអាយុ ១២ ឆ្នាំ និងកូនប្រុស អាយុ ៥ឆ្នាំ ។

ដោយសារកូនៗធំឡើងពីមួយថ្ងៃទៅមួយថ្ងៃ អ្នកស្រី ប៊ុនរ័ត្ន និងស្វាមីបានសម្រេចចិត្តសាងសង់ផ្ទះមួយខ្នងសម្រាប់កូនៗ ក៏ដូចជាដើម្បីអាជីវកម្មរបស់ខ្លួន ។ អ្នកស្រីបានលើកឡើងថា៖ "ក្នុងតួនាទីជាឪពុកម្តាយ កាតព្វកិច្ចរបស់យើងគឺផ្តល់ទីកន្លែងដែលសមរម្យសម្រាប់កូនៗរៀនសូត្រ និងលេងសប្បាយនៅពេលពួកគេទំនេរនៅផ្ទះ ។ យើងខ្ញុំមានមោទនភាពណាស់ដែលបានសម្រេចកិច្ចការនេះ។"

បើទោះបីចំណូលមានកម្រិតក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារក៏ដោយក៏ អ្នកស្រី ប៊ុនរ័ត្ន និងស្វាមីនៅតែអាចសន្សំលុយទិញដីបានមួយឡូត៍នៅជិតកន្លែងដែលពួកគាត់រស់នៅ ។ ពួកគាត់បន្តខិតខំសន្សំបន្ថែមទៀតដើម្បីផ្តល់នូវជីវិត និងផ្ទះដ៏សមរម្យមួយសម្រាប់កូនៗរបស់ពួកគាត់ ។

តាមរយៈប្រាក់សន្សំពួកគាត់បានចាប់ផ្តើមសង់ផ្ទះ ប៉ុន្តែប្រាក់ទាំងនោះអាចត្រឹមបង្ហើយផ្ទះតែ ៨០% ប៉ុណ្ណោះ ។ ពួកគាត់ដឹងខ្លួនថាមិនមានប្រាក់បន្ថែមដើម្បីសង់បង្ហើយនោះទេ ។ ជាមួយចំណូលចំនួន ៥៥០ ដុល្លារក្នុងមួយខែ ពីអាជីវកម្ម បញ្ចូលហ្គាសសម្រាប់ដាំស្ល និងស្វាមីធ្វើជាជាងសំណង់ ពួកគាត់បានសម្រេចចិត្តស្នើកម្ចីកែលម្អផ្ទះពី ហ្វីស ហ្វាយនែន ចំនួន ៥.២៥០ ដុល្លារ ដើម្បីបង្ហើយផ្ទះ ។ ឥឡូវនេះពួកគាត់បានរើមកនៅផ្ទះថ្មី បើទោះជាផ្នែកខ្លះកំពុងធ្វើ ហើយនឹងបញ្ចប់នៅពេលឆាប់ៗ នេះ។

"ខ្ញុំពិតជាអរគុណខ្លាំងណាស់ដល់ ហ្វីស ហ្វាយនែនដែលបានផ្តល់កម្ចីដើម្បីបង្ហើយផ្ទះ លើសពីនេះក៏អាចពង្រីកអាជីវកម្មផងដែរ ពីព្រោះខ្ញុំមានទីតាំងទូលាយអាចប្រកបរបរបាន។" អ្នកស្រីបន្ថែម



# អំពី ហ្វឺស ហ្វាយនែន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ភីអិលស៊ី ធ្លាប់ជាក្រុមហ៊ុនដែលបណ្តាក់ទុនរួមគ្នារវាង ក្រុមហ៊ុន ហ្វឺស ហូម ភីអិលស៊ី ដែលមានទីតាំងក្នុងប្រទេសកម្ពុជា Phillip Capital ដែលមានទីតាំងក្នុងប្រទេសសិង្ហបុរី Insitor Fund ដែលមានទីតាំងក្នុងប្រទេសលុចសំបួរ មូលនិធិអភិវឌ្ឍន៍កម្ពុជា ឡាវ (Cambodia-Laos Development Fund) និង Norfund ដែលមានទីតាំងក្នុងប្រទេសន័រវេស។ មកដល់ខែមិថុនា ឆ្នាំ ២០២២ ភាគហ៊ុន ១00% ត្រូវបានផ្ទេរ ដោយស្ថិតនៅក្រោមការគ្រប់គ្រងក្រុមហ៊ុនក្នុងស្រុក។

ហ្វឺស ហ្វាយនែន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ហើយបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស ក្នុងការផ្តល់ឥណទានលំនៅដ្ឋានខ្នាតតូចមុនគេក្នុងប្រទេសកម្ពុជា ។ ហ្វឺស ហ្វាយនែន ផ្តោតទៅលើការផ្តល់ប្រាក់កម្ចីទិញផ្ទះ និងសាងសង់ផ្ទះរយៈពេលវែង ក៏ដូចជាកម្ចីអចលទ្រព្យធានារយៈពេលមធ្យម ទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដែលភាគតិចណាស់ មានលទ្ធភាពប្រើប្រាស់សេវាកម្ចីលំនៅដ្ឋានរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការនានា ។ ភាគច្រើននៃធនាគារពាណិជ្ជផ្តល់សេវាដល់អតិថិជនដែលមានចំណូលខ្ពស់ ។

## ទស្សនៈវិជ្ជាអាជីវកម្មរបស់យើង

ទស្សនៈវិជ្ជាអាជីវកម្មរបស់យើងមានភាពសាមញ្ញ៖ **យើងគិតដូចជាអតិថិជន និងអនុវត្តដូចជាម្ចាស់**

ផ្តល់សេវា និងផលិតផលដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ

ផ្តល់នូវនីតិវិធីដែលមានភាពរហ័ស និងងាយស្រួល

ធ្វើប្រតិបត្តិការប្រកបដោយភាពបត់បែន និងមានតម្លាភាព

បង្ហាញពីភាពសុចរិតទៀងត្រង់ និងសីលធម៌ក្នុងការអនុវត្តអាជីវកម្ម

# ចក្ខុវិស័យរបស់យើង

ជួយឲ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប បានរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុវត្ថិភាព សុភមង្គល និងមានស្ថេរភាព តាមរយៈការផ្តល់លទ្ធភាពឲ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន

# បេសកកម្មរបស់យើង

បង្កើតស្ថេរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប តាមរយៈការផ្តល់សេវាឥណទានដើម្បីឲ្យពួកគាត់ក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង

# គុណតម្លៃរបស់យើង

**សុចរិតភាព**
ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់យើង យើងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងមានតម្លាភាពគ្រប់សកម្មភាពការងាររបស់យើង ។

**ការឆ្លើយតប**
យើងតែងនៅកៀកស្និទ្ធជាមួយអតិថិជនគ្រប់គ្រាន់ល្មម ដែលអាចឲ្យយើងផ្តល់ការយកចិត្តទុកដាក់ និងឆ្លើយតបតម្រូវការរបស់ពួកគាត់ទាន់ពេលវេលា ។ យើងក៏មានទំនួលខុសត្រូវគ្រប់ទង្វើរបស់យើង និងបើកចិត្តទូលាយក្នុងការទទួលយកការរិះគន់ដើម្បីស្តាបនាផងដែរ ។

**ភាពច្នៃប្រឌិតខ្ពស់**
យើងមានគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាពដើម្បីបម្រើអតិថិជនរបស់យើងឲ្យកាន់តែប្រសើរជាងមុន ។

**ភាពស្មើគ្នា**
យើងមានមោទនភាពចំពោះការគោរព ការមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និងការបម្រើដល់អតិថិជនដោយស្មើភាព។

**ឧត្តមភាព**
ការងាររបស់យើង គឺធ្វើឡើងដោយអស់ពីកម្លាំងកាយចិត្ត។



# សាវតានៃដំណើរវិវឌ្ឍន៍

**២០០៦ - ២០០៩**




## មូលដ្ឋានគ្រឹះ និងអាជ្ញាបណ្ណ

- ហ្វឺស ហ្វូម ត្រូវបានបង្កើតឡើង ដែលមានម្ចាស់ភាគហ៊ុន First Home, Insitor Fund, និង Phillip Capital
- មានតម្រូវការលើផលិតផលកម្ចីទិញផ្ទះ
- ទទួលបានអាជ្ញាបណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៩

**២០១០ - ២០១៣**



## ចាប់ផ្តើមដំណើរការ និងរីកធំធាត់

- ទទួលបានភាគទុនពី CLDF, Norfund
- ទទួលបានហិរញ្ញប្បទានពី Oikocredit, Finnfund, Norfund និងធនាគារក្នុងស្រុក
- ពង្រីកប្រតិបត្តិការ ដោយបើកសាខាថ្មី រួមជាមួយអភិបាលកិច្ចសាជីវកម្ម និងគ្រប់គ្រងហានិភ័យ
- ទទួលបានពានរង្វាន់អាជីវកម្មឆ្នើមប្រចាំអាស៊ីក្នុងឆ្នាំ ២០២២

**២០១៤ - ២០១៥**



## ការកែប្រែលើហានិភ័យ

- ប្រឈមមុខការកើនឡើងកម្ចីមិនដំណើរការខ្ពស់ ដោយផ្តោតលើការដោះស្រាយ
- កែប្រែគោលនយោបាយឥណទាន
- បណ្តុះបណ្តាលលើការវាយតម្លៃឥណទាន និងកំហិតតឹងរ៉ឹងលើដំណើរការសិក្សាកម្ចី

**២០១៦ - ២០១៩**



## គ្រប់គ្រងការរីកធំធាត់

- ទទួលបានហិរញ្ញប្បទានពី Phillip, Norfund, Symbiotics, Triple Jump, Water Equity.
- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មាន និងធនាគារស្នូលថ្មី
- ធ្វើប្រសើរឡើងលើការត្រួតពិនិត្យហិរញ្ញវត្ថុ



## វិបត្តិកូវីដ និងការកើនឡើងកម្ចីមិនល្អ

- អនុគ្រោះកម្ចីដែលប៉ះពាល់ដោយកូវីដ រៀបចំកម្ចីឡើងវិញ រឹតបន្តឹងការត្រួតពិនិត្យហានិភ័យ
- ទាក់ទាញប្រភពហិរញ្ញប្បទានថ្មីៗ
- ពង្រីកកិច្ចសហការជាដៃគូជាមួយ អ្នកអភិវឌ្ឍន៍អចលនទ្រព្យ

**២០២២-ទៅពេលខាងមុខ**

**២០២០ - ២០២១**



## ភាគទុនិកថ្មី និងសន្ទុះនៃការរីកចម្រើន

- ផ្លាស់ប្តូរភាគទុនិកថ្មី (គ្រប់គ្រងដោយគណៈគ្រប់គ្រងថ្មី) ។ ចុះបញ្ជីបង្កើនដើមទុនបន្ថែម
- បង្កើត និងធ្វើឱ្យប្រសើរឡើងលើគ្រប់នីតិវិធី និងដំណើរការផ្សេងៗដូចជា អភិបាលកិច្ចសាជីវកម្ម គ្រប់គ្រងហានិភ័យ និងគ្រប់គ្រងផ្ទៃក្នុង
- ធ្វើឱ្យប្រសើរឡើង ទៅលើប្រសិទ្ធិភាព ផលិតភាព និងប្រាក់ចំណេញ ដោយបង្កើតសាខាថ្មី ត្រួតពិនិត្យគុណភាព និងបង្កើនផលបត្រឥណទាន

# នាមស្ថាប័នផ្តល់ហិរញ្ញប្បទាន

OIKO CREDIT in Menschen investieren

symbiotics

BlueOrchard Microfinance Investment Managers

Norfund

Triple Jump

WATEREQUITY

PPCBank

lendahand

BlueEarth CAPITAL

PhillipBank Your Partner In Finance

Wing Bank

Cargill

SAISON CAPITAL

L'Officina di Enrico Onlus

# រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន



# ក្រុមប្រឹក្សាភិបាល



## HANCO HALBERTSMA

### ប្រធានក្រុមប្រឹក្សាភិបាល

លោក Hanco Halbertsma គឺជាទីប្រឹក្សាផ្នែកយុទ្ធសាស្ត្រសម្រាប់ធនាគារ ស្ថាប័នហិរញ្ញវត្ថុ និងស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងសម្រាប់អ្នកដែលចង់វិនិយោគលើស្ថាប័នហិរញ្ញវត្ថុ ។ ក្នុងរយៈពេលជាង ២៥ ឆ្នាំកន្លងទៅនេះ លោកបានធ្វើការក្នុងគម្រោងជាច្រើនជាអ្នកជំនាញវិស័យហិរញ្ញវត្ថុ ដែលរួមមាន ផ្នែកមីក្រូហិរញ្ញវត្ថុ ផ្នែកធនាគារសម្រាប់អាជីវកម្ម និងបុគ្គលហិរញ្ញវត្ថុសហគ្រាសខ្នាតតូច ការគ្រប់គ្រងហានិភ័យឥណទាន អភិបាលកិច្ចសាជីវកម្ម និងផ្នែកហិរញ្ញប្បទាន ។

ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាភិបាលរបស់ ហ្វីស ហ្វាយនែន លោក Hanco ផ្តល់ការគាំទ្រផ្នែកយុទ្ធសាស្ត្រ ផ្នែកស្វែងរកមូលនិធិ ផ្នែកគ្រប់គ្រងហានិភ័យឥណទាន ផ្នែកហិរញ្ញវត្ថុ និងផ្នែកកសាងសមត្ថភាពបុគ្គលិក។ មុនពេលចាប់ផ្តើមជាមួយហ្វីស ហ្វាយនែន លោកមានបទពិសោធន៍ក្នុងប្រទេសកម្ពុជា ចំនួន៦ឆ្នាំមកហើយក្នុងនាមជាអភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេក្នុងប្រទេសកម្ពុជា ។ លោកក៏ធ្លាប់ដើរតួនាទីជាអភិបាល របស់ក្រុមហ៊ុនមួយចំនួននៅក្នុងទីក្រុងហុងកុង ឥណ្ឌា និងស្រីលង្ការ ។

លោក Hanco គឺជាស្ថាបនិកក្រុមហ៊ុន Priority Project Limited (PPL) ដែលជាក្រុមហ៊ុនជំនាញក្នុងការប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្ត្រ និង ផ្នែកប្រតិបត្តិការសម្រាប់ស្ថាប័នហិរញ្ញវត្ថុ និងវិនិយោគិនក្នុងតំបន់អាស៊ី។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើង បន្ទាប់ពីលោកបានធ្វើការក្នុងក្រុមហ៊ុន ING Group អស់រយៈពេល១៦ឆ្នាំ ដែលក្នុងនោះរយៈពេល៨ឆ្នាំ គឺលោកបានធ្វើក្នុងក្រុមហ៊ុន ING-IGA ដែលជាក្រុមហ៊ុនពិគ្រោះយោបល់ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

លោក Hanco បានបញ្ចប់ការសិក្សា ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម ហើយគាត់កំពុងធ្វើការក្នុងទីក្រុងហុងកុង។



## លោក ស៊ូ វណ្ណថន

### អភិបាលឯករាជ្យ

លោក ស៊ូ វណ្ណថន បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ និងបញ្ចប់ការសិក្សាផ្នែកធនាគារក្នុងឆ្នាំ ១៩៨៨ ។ លោកត្រូវបានទទួលស្គាល់ដោយស្ថាប័ន CGAP & EDA Rural Systems Pty Ltd ជាគ្រូបង្គោលលើការបណ្តុះបណ្តាលផ្នែកគោលការណ៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងការដោះស្រាយបំណុល ។ ចាប់តាំងពីឆ្នាំ ១៩៨២ មក លោកបានចូលរួមវគ្គសិក្សាជាច្រើន ដែលពាក់ពន្ធ័ការគ្រប់គ្រងប្រតិបត្តិការធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស ។

លោកមានបទពិសោធន៍ច្រើនជាង ៣០ឆ្នាំ ក្នុងតួនាទីជាច្រើនជាមួយ ប្រាសាក់ ធនាគារជាតិ ក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងនោះមានដូចជាមន្ត្រីឥណទាន អ្នកសម្របសម្រួលឥណទានថ្នាក់ខេត្ត អនុប្រធានផ្នែកឥណទាន ប្រធានសាខា ប្រធានតំបន់ និងប្រធានភូមិភាគ ។ លោកបានបម្រើការនៅប្រាសាក់ម្តងទៀត ជាប្រធានផ្នែកធនធានមនុស្សក្នុងឆ្នាំ ២០០៩។

លោកត្រូវបានតម្លើងតំណែង ជានាយកប្រតិបត្តិគ្រប់គ្រងធនធានមនុស្សក្នុងឆ្នាំ ២០១០ ហើយបានចូលនិវត្តន៍ក្នុងឆ្នាំ ២០១៧ ។ បច្ចុប្បន្នលោកកាន់តួនាទីជាអភិបាលឯករាជ្យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ។



## អ៊ុំ សូផន

### អភិបាល

លោក អ៊ុំ សូផន បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និងថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុ ។ មុនពេលបម្រើការងារនៅប្រាសាក់ លោកមានបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងការគ្រប់គ្រងគណនេយ្យ គ្រប់គ្រងហិរញ្ញវត្ថុ និងធនាគារ និងធ្លាប់បម្រើការងារក្នុងឋានៈជា នាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជ ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនឯកជននានា ។ លោក ចូលបម្រើការងារនៅ ប្រាសាក់ ក្នុងតួនាទីជាអគ្គនាយករងទទួលបន្ទុកហិរញ្ញវត្ថុ នៅក្នុងឆ្នាំ ២០០៧ រហូតមកដល់ដើមឆ្នាំ ២០២២។ បច្ចុប្បន្នលោកមានតួនាទីជាអភិបាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន។



## ស៊ីម សេនាជាតិ

### អភិបាល

លោក ស៊ីម សេនាជាតិ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម និងបញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុក្នុងឆ្នាំ ១៩៩៤ ។ ចាប់តាំងពីឆ្នាំ ១៩៩៥ មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ពាក់ពន្ធ័និងការគ្រប់គ្រង និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។ លោកក៏ត្រូវបានទទួលស្គាល់ជាគ្រូបង្គោលមីក្រូហិរញ្ញវត្ថុដោយ ADBI និង TDLC របស់ធានាគារពិភពលោក និង UNCDF ។

លោកធ្លាប់បានធ្វើការងារជាច្រើនក្នុងវិស័យធនាគារ និងបានចាប់ផ្តើមបំពេញការងារជាមួយប្រាសាក់ ចាប់តាំងពីឆ្នាំ ១៩៩៥ ក្នុងតួនាទីជាមន្ត្រីឥណទាន និងត្រូវបានតំឡើងឋានៈ ក្នុងមុខតំណែងផ្សេងៗជាច្រើន ដូចជា គណនេយ្យករ នាយកសាខា គ្រូបង្គោលផ្នែកកម្មវិធី MB អ្នកត្រួតពិនិត្យ និងនាយកហិរញ្ញវត្ថុ ។ ចាប់ពីពាក់កណ្តាលឆ្នាំ ២០០២ មក លោកបម្រើការងារក្នុងតួនាទីជានាយសាខា នាយកប្រតិបត្តិការ និងជាអនុប្រធាននាយកប្រតិបត្តិនៅគ្រឹះស្ថានមួយផ្សេងទៀត មុននឹងចូលមកបម្រើការងារ ជាប្រធាននាយកប្រតិបត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នៅចុងឆ្នាំ ២០០៣ រហូតមកដល់ដើមឆ្នាំ ២០២២។ បច្ចុប្បន្នលោកមានតួនាទីជាអភិបាល និងជាប្រធាននាយកប្រតិបត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ។



## ជា ហាង

### អភិបាល

លោក ជា ហាង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និងបញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ។ លោកមានបទពិសោធន៍ជាច្រើនខាងផ្នែកហិរញ្ញវត្ថុ គណនេយ្យ លទ្ធកម្ម ការគ្រប់គ្រងធនធានមនុស្ស ឥណទាន សេវាធនាគារ គោលនយោបាយអង្គភាព ច្បាប់ អភិបាលកិច្ចអាជីវកម្ម យុទ្ធសាស្ត្រអាជីវកម្ម ផែនការអាជីវកម្ម និងការគ្រប់គ្រងគម្រោង ។

លោកធ្លាប់បានបម្រើការងារក្នុងតួនាទីជាច្រើន ដូចជាប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល អ្នកប្រឹក្សាជាន់ខ្ពស់ផ្នែកលទ្ធកម្មហិរញ្ញវត្ថុ និងរដ្ឋបាល ប្រធានក្រុមប្រឹក្សាភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ នាយកប្រតិបត្តិ និងប្រធាននាយកដ្ឋានជាន់ខ្ពស់ផ្នែកយុទ្ធសាស្ត្រ និងផែនការអាជីវកម្ម ហើយលោកត្រូវបានតម្លើងតំណែង ជាប្រធាននាយកប្រតិបត្តិទទួលបន្ទុកផ្នែកយុទ្ធសាស្ត្រ និងផែនការអាជីវកម្ម។ លោកក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបុគ្គលិកប្រាសាក់ (PSCo) និង ជាប្រធានក្រុមប្រឹក្សាភិបាលរបស់បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ ។ បច្ចុប្បន្នលោកកាន់តួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាអភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ។



# គណៈគ្រប់គ្រង







## ស៊ឹម សេនាជាតិ
### ប្រធាននាយកប្រតិបត្តិ

លោក ស៊ឹម សេនាជាតិ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម និងបញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុក្នុងឆ្នាំ ១៩៩៤ ។ ចាប់តាំងពីឆ្នាំ ១៩៩៥ មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ពាក់ពន្ធ័និងការគ្រប់គ្រង និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។ លោកក៏ត្រូវបានទទួលស្គាល់ជាគ្រូបង្គោលមីក្រូហិរញ្ញវត្ថុដោយ ADBI និង TDLC របស់ធានាគារពិភពលោក និង UNCDF ។

លោកធ្លាប់បានធ្វើការងារជាច្រើនក្នុងវិស័យធនាគារ និងបានចាប់ផ្តើមបំពេញការងារជាមួយប្រាសាក់ ចាប់តាំងពីឆ្នាំ ១៩៩៥ ក្នុងតួនាទីជាមន្ត្រីឥណទាន និងត្រូវបានតំឡើងឋានៈ ក្នុងមុខតំណែងផ្សេងៗជាច្រើន ដូចជា គណនេយ្យករ នាយកសាខា គ្រូបង្គោលផ្នែកកម្មវិធី MB អ្នកត្រួតពិនិត្យ និងនាយកហិរញ្ញវត្ថុ ។ ចាប់ពីពាក់កណ្តាលឆ្នាំ ២០០២ មក លោកបម្រើការងារក្នុងតួនាទីជានាយសាខា នាយកប្រតិបត្តិការ និងជាអនុប្រធាននាយកប្រតិបត្តិនៅគ្រឹះស្ថានមួយផ្សេងទៀត មុននឹងចូលមកបម្រើការងារ ជាប្រធាននាយកប្រតិបត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នៅចុងឆ្នាំ ២០០៣ រហូតមកដល់ដើមឆ្នាំ ២០២២។ បច្ចុប្បន្នលោកមានតួនាទីជាអភិបាល និងជាប្រធាននាយកប្រតិបត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ។

## ជា ហាង
### អនុប្រធាននាយកប្រតិបត្តិ

លោក ជា ហាង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និងបញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ។ លោកមានបទពិសោ-ធន៍ជាច្រើនខាងផ្នែកហិរញ្ញវត្ថុ គណនេយ្យ លទ្ធកម្ម ការគ្រប់គ្រងធនធានមនុស្ស ឥណទាន សេវាធនាគារ គោលនយោបាយអង្គភាព ច្បាប់ អភិបាលកិច្ចអាជីវកម្ម យុទ្ធសាស្ត្រអាជីវកម្ម ផែនការអាជីវកម្ម និងការគ្រប់គ្រងគម្រោង ។

លោកធ្លាប់បានបម្រើការងារក្នុងតួនាទីជាច្រើន ដូចជាប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល អ្នកប្រឹក្សាជាន់ខ្ពស់ផ្នែកលទ្ធកម្មហិរញ្ញវត្ថុ និងរដ្ឋបាល ប្រធានក្រុមប្រឹក្សាភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ នាយកប្រតិបត្តិ និងប្រធាននាយកដ្ឋានជាន់ខ្ពស់ផ្នែកយុទ្ធសាស្រ្ត និងផែនការអាជីវកម្ម ហើយលោកត្រូវបានតម្លើងតំណែង ជាប្រធាននាយកប្រតិបត្តិទទួលបន្ទុកផ្នែកយុទ្ធសាស្រ្ត និងផែនការអាជីវកម្ម។ លោកក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបុគ្គលិកប្រាសាក់ (PSCo) និង ជាប្រធានក្រុមប្រឹក្សាភិបាលរបស់បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ ។ បច្ចុប្បន្នលោកកាន់តួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាអភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ។

## នាង សុខឃីម
### នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ

លោក នាង សុខឃីម បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង និងជាគ្រូបង្គោលមីក្រូហិរញ្ញវត្ថុ ដែលទទួលស្គាល់ដោយ ADBI, TLDC របស់ធនាគារពិភពលោក និង UNCDF ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រក្សេត្រសាស្រ្តនៅឆ្នាំ ១៩៩៧ ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ទាក់ទងនឹងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតផងដែរ។

លោកមានបទពិសោធន៍ច្រើនជាង ២០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយចាប់ផ្តើមពីតួនាទីជាមន្ត្រីឥណទាន ក្នុងឆ្នាំ ១៩៩៨ ហើយត្រូវបានដំឡើងតួនាទីជាបន្តបន្ទាប់ ជាសវនករផ្ទៃក្នុង សវនករផ្ទៃក្នុងជាន់ខ្ពស់ នាយករងប្រតិបត្តិការ នាយករងឥណទាន និងជានាយកឥណទាន ។ លោកត្រូវបានដំឡើងតួនាទី ជានាយកប្រតិបត្តិទទួលបន្ទុកអាជីវកម្មចាប់តាំងពីឆ្នាំ ២០១០ រហូតមកដល់ដើមឆ្នាំ ២០២២។ បច្ចុប្បន្ននេះ លោកមានតួនាទីជានាយកប្រត្តិបត្តិគ្រប់គ្រងហានិភ័យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន។



## យ៉ាង គឹមស្រេង

### នាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ

លោកយ៉ាង គឹមស្រេង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្មឯកទេសធនាគារ និងហិរញ្ញ-វត្ថុ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ និងបញ្ចប់ការសិក្សា ថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ។ លោកមានបទពិសោធន៍ច្រើនឆ្នាំ ក្នុងផ្នែកហិរញ្ញវត្ថុ គណនេយ្យ ហិរញ្ញកិច្ចលទ្ធកម្ម និងសេវាកម្មធនាគារ។ លោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើន ដែលទាក់ទងនឹងវិស័យមីក្រូហិរញ្ញវត្ថុទាំងនៅក្នុងស្រុក និងអន្តរជាតិទាំងតំបន់អាស៊ី និងអឺរ៉ុប។

លោកមានបទពិសោធន៍ច្រើនជាង ២៣ឆ្នាំ នៅក្នុងវិស័យ ធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ លោកបានចំណាយពេលជាង ១៦ឆ្នាំ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ ។ លោកចាប់ផ្តើមពីតួនាទីជាគណនេយ្យករនៅប្រាសាក់ ក្នុងឆ្នាំ ១៩៩៨ ហើយត្រូវបានតំឡើងតំណែងជាបន្តបន្ទាប់ ពីប្រធានគណនេយ្យ ប្រធានផ្នែកគាំទ្រមីក្រូប៉េងយី អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នាយកនាយកដ្ឋានហិរញ្ញវត្ថុ ។ លោកត្រូវបានដំឡើងតួនាទី ជានាយកជាន់ខ្ពស់នាយកដ្ឋានហិរញ្ញវត្ថុ ចាប់ពីឆ្នាំ២០១៧ ដល់ដើមឆ្នាំ២០២២ ។ បច្ចុប្បន្នលោកកាន់តួនាទីជានាយកប្រតិបត្តិគ្រប់គ្រងហិរញ្ញវត្ថុ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ។



## សាយ សុនី

### នាយកប្រតិបត្តិគ្រប់គ្រងទីផ្សារ

លោក សាយ សុនី បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និងជាគ្រូបង្គោលមីក្រូហិរញ្ញវត្ថុ ដែលទទួលស្គាល់ដោយ ADBI, TLDC របស់ធនាគារពិភពលោក និង UNCDF ។ លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទីផ្សារ ហើយលោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាំងនៅតំបន់អាស៊ី និងអឺរ៉ុបទាក់ទងនឹងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ការអភិវឌ្ឍផលិតផល ការគ្រប់គ្រងអតិថិជន និងការគ្រប់គ្រងទីផ្សារ ។

លោកមានបទពិសោធន៍ជាង ២០ឆ្នាំ លើការគ្រប់គ្រងគម្រោង ការគ្រប់គ្រងទីផ្សារ ការអភិវឌ្ឍន៍ផលិតផល និងការគ្រប់គ្រងទាំងក្នុងវិស័យឯកជនការងារសង្គម និងមីក្រូហិរញ្ញវត្ថុ ។ លោកបានចូលរួមបម្រើការងារនៅប្រាសាក់ក្នុងដើមឆ្នាំ ២០០៥ ក្នុងតួនាទីជាប្រធានផ្នែកទីផ្សារ និងត្រូវបានតំឡើងតួនាទីជានាយកគ្រប់គ្រងទីផ្សារ ក្នុងឆ្នាំ ២០០៧ ។ លោកត្រូវបានតំឡើងតួនាទីជានាយកប្រតិបត្តិទទួលបន្ទុកទីផ្សារ ចាប់ពីឆ្នាំ ២០១០ រហូតមកដល់ដើមឆ្នាំ ២០២២ ។ បច្ចុប្បន្នលោកកាន់តួនាទីជានាយកប្រតិបត្តិគ្រប់គ្រងទីផ្សារ នៃគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ។



## ជួប វាសនា

### នាយកប្រតិបត្តិគ្រប់គ្រងប្រតិបត្តិការ

លោក ជួប វាសនា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម និងបរិញ្ញាបត្រសេដ្ឋកិច្ចឯកទេសហិរញ្ញវត្ថុ និងធនាគារ ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ទាក់ទងនឹងការអភិវឌ្ឍន៍ជំនាញមីក្រូហិរញ្ញវត្ថុទាំងក្នុង និងក្រៅប្រទេស ។

លោកមានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ លោកបានចូលរួមបម្រើការងារនៅប្រាសាក់ក្នុងឆ្នាំ ២០០២ ក្នុងតួនាទីជាមន្ត្រីឥណទាន ។ ជាបន្តបន្ទាប់ លោកត្រូវបានតំឡើងតួនាទី ជានាយកអនុសាខា នាយកសាខា និងជាប្រធានផ្នែកឥណទាន ។ ក្នុងឆ្នាំ ២០១០ លោកត្រូវបានដំឡើងតួនាទីជានាយកនាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍផលិតផល។ លោកត្រូវបានតំឡើងតួនាទី ជាអនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស ចាប់ពីឆ្នាំ ២០២០ រហូតមកទល់ដើមឆ្នាំ ២០២២ ។ បច្ចុប្បន្នលោកកាន់តួនាទី ជានាយកប្រតិបត្តិគ្រប់គ្រងប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ។

# ទិដ្ឋភាពទូទៅនៃអាជីវកម្ម

## ធនធានអាជីវកម្ម ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍន៍

២០២២ គឺជាឆ្នាំដែលត្រូវបន្តសន្ទុះដែលសម្រេចបាននៅក្នុងឆ្នាំ ២០២១ ទៅលើកិច្ចការចូលរួម និងភាពជាអ្នកដឹកនាំ ។ ដើម្បីគាំទ្រទៅដល់ការរីកចម្រើនឥតឈប់ឈរ ហ្វីស ហ្វាយនែន បានជ្រើសរើសបុគ្គលិកបន្ថែម ដែលចំនួនបុគ្គលិកបានកើនឡើងស្ទើរតែ ១00% ពី ១០៩ ទៅ ១៩៤ នាក់ត្រឹមរយៈពេល ៦ខែចុងក្រោយ ។ ក្នុងចំណោម ១៩៤ នាក់ ប្រមាណ ២0% ជាថ្នាក់គ្រប់គ្រង ៤៨% ជាបុគ្គលិកជួរមុខ ចំណែកឯ ៣២% ទៀតគឺជា បុគ្គលិកគាំទ្រ ។

ដោយប្រកាន់ខ្ជាប់គុណតម្លៃ “IRISE” វគ្គបណ្ដុះបណ្ដាលត្រូវបានធ្វើឡើងជាប្រចាំសម្រាប់បុគ្គលិក ហ្វីស ហ្វាយនែន គ្រប់រូប ដើម្បីឱ្យប្រាកដថា ពួកគេបានត្រូវត្រៀមជាស្រេចក្នុងការផ្ដល់ជូនសេវាកម្មដែលមានគុណភាពល្អទៅកាន់អតិថិជន ក៏ដូចជាផ្ដល់ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍អាជីពការងាររបស់ពួកគេផងដែរ។ ការបណ្ដុះបណ្ដាលត្រូវបានផ្ដល់ដល់បុគ្គលិកថ្មី អំពីផលិតផល គោលនយោបាយទាំងចាស់និងថ្មី និងវគ្គបណ្ដុះបណ្ដាលពិសេស ដូចជា គោលនយោបាយធនធានមនុស្ស ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយឥណទាន គោលនយោបាយប្រឆាំងនឹងការលាងលុយកខ្វក់ AML/CFT ។ ល។

ផ្នែកបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ បានផ្ដល់នូវវគ្គបណ្ដុះបណ្ដាលលើមុខវិជ្ជាផ្សេងៗជាច្រើនប្រកបដោយវិជ្ជាជីវៈ ទៅកាន់បុគ្គលិកចូលថ្មីចំនួន ១៤៨ និងជួយសម្របសម្រួលដល់វគ្គបណ្ដុះបណ្ដាលខាងក្រៅជូនដល់បុគ្គលិកចំនួន ២២ រូប ។



**១00%**
កំណើនបុគ្គលិក



**១៧0**
ចំនួនវគ្គបណ្ដុះបណ្ដាល

## ការផ្ដោតជាសំខាន់ទៅលើអតិថិជន

ហ្វីស ហ្វាយនែន ជឿថាសេវាអតិថិជន មានសារៈសំខាន់សម្រាប់ការរីកចម្រើនរបស់អាជីវកម្មប្រកបដោយស្ថេរភាព ។ យើងតែងតែទទួលយកមតិរិះគន់ និងផ្ដល់យោបល់ដោយយកចិត្តទុកដាក់ ដើម្បីឱ្យប្រាកដថាអតិថិជនទទួលបានសេវាល្អនៅគ្រប់ចំនុចដែលអតិថិជនមានអន្តរកម្មជាមួយស្ថាប័ន ។ ការផ្ដល់មតិយោបល់ត្រូវបានប្រមូលតាមរយៈការស្ទង់មតិនៅពេលក្លាយជាអតិថិជន និងនៅពេលដែលចាកចេញ ។ ក្នុងឆ្នាំ ២០២២ យើងខ្ញុំបានទទួលបណ្ដឹងចំនួន ៨ ពីអតិថិជន ។ ហេតុដូច្នេះហើយយើងខ្ញុំតែងតែបន្តការធ្វើឱ្យប្រសើរឡើងទៅលើនីតិវិធី និងដំណើរការមួយចំនួន ។ កិច្ចការទាំងនេះ បានធ្វើឱ្យយើងក្លាយជាស្ថាប័នលេចធ្លោនៅក្នុងទីផ្សារ ដែលបានផ្ដល់នូវសេវាប្រកបដោយការច្នៃប្រឌិតខ្ពស់ទៅដល់អតិថិជន ។

អតិថិជនថ្មីចំនួន ៧៧៨ គ្រួសារបានទទួលប្រើសេវាឥណទានពីហ្វីស ហ្វាយនែន នៅក្នុងឆ្នាំ ២០២២ ។ ៦៥% នៃអតិថិជនសរុបគឺជាស្ត្រី។ កម្រិតអតិថិជនដែលនៅតែបន្តប្រើប្រាស់សេវារបស់ ហ្វីស ហ្វាយនែន មានចំនួន ៩៨,៤% ។



**៧៧,៣%**
កម្រិតថែរក្សាអតិថិជន



**៧៧៨**
ចំនួនអតិថិជនថ្មី

## កសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ដើម្បីត្រៀមជាស្រេចសម្រាប់ការរីកចម្រើននាពេលដ៏ខ្លីខាងមុខ

ក្នុងរយៈពេល ១៣ឆ្នាំ រាប់ចាប់តាំងពីពេលដែលត្រូវបានបង្កើត ហ្វីស ហ្វាយនែន នៅតែរក្សាបេសកកម្មក្នុងការគាំទ្រដល់ប្រជាជនដែលមានចំណូលទាប និងមធ្យមនៅក្នុងប្រទេសកម្ពុជាតាមរយៈការផ្ដល់នូវសេវាកម្ចីលំនៅដ្ឋានខ្នាតតូចរយៈពេលវែង ដើម្បីឱ្យពួកគាត់មានលទ្ធភាពមានផ្ទះដ៏សមរម្យមួយជាកម្មសិទ្ធិផ្ទាល់ខ្លួន អាច

រស់នៅក្នុងជីវភាពមួយប្រកបដោយស្ថេរភាព ។ ក្នុងរយៈពេលជាង ១០ឆ្នាំកន្លងមកនេះ ហ្វីស ហ្វាយនែន បានចូលរួមចំណែកជួយដល់សង្គម ដោយបានជួយជ្រោមជ្រែងដល់ប្រជាជនប្រមាណជាង ៤៥០០ គ្រួសារ មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនជាលើកដំបូងនៅក្នុងជីវិត ។

ដើម្បីពង្រីកវិសាលភាព ក្នុងការផ្តល់សេវាកម្ចីលំនៅដ្ឋានខ្នាតតូចរយៈពេលវែងជូនដល់ប្រជាជនដែលមានចំណូលទាប និងមធ្យមឱ្យបានកាន់តែច្រើនថែមទៀត ហ្វីស ហ្វាយនែន បានចុះបញ្ជីតម្លើងដើមទុនបន្ថែមរហូតដល់ ១៥លានដុល្លារអាមេរិក នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២២ ។ ការដំឡើងដើមទុននេះ ក៏ជាផ្នែកមួយក្នុងការកសាងទំនុកចិត្តពីសាធារណជន ក៏ដូចជាបុគ្គលិកផ្ទាល់ ដោយវាបានបង្ហាញអំពីគ្រឹះរឹងមាំរបស់ស្ថាប័ន ។



**១៥លានដុល្លារ**
ចុះបញ្ជីបង្កើនដើមទុន

## ការរីកចម្រើនប្រកបដោយគុណភាព

បើទោះបី ការរាតត្បាតជាសកលត្រូវបានកាត់បន្ថយក៏ដោយ ក៏ឆ្នាំ ២០២២ នៅតែជាឆ្នាំដែលប្រឈមសម្រាប់ការរីកចម្រើន ។ ដោយសម្របទៅតាមស្ថានការណ៍នេះ យើងខ្ញុំបានកែប្រែយុទ្ធសាស្ត្រ និងយន្តការនៃការលក់ ព្រមជាមួយការបង្កើនគុណភាពក្នុងការវាយតម្លៃឥណទាន ដើម្បីធានាបានថាការរីកចម្រើនរបស់យើងខ្ញុំ ប្រកបដោយគុណភាព ។ ជាលទ្ធផលផលបត្រឥណទានបានកើនឡើងប្រមាណ ១៧% ដោយកើនពី ៣០,៥លានដុល្លារ ក្នុងឆ្នាំ ២០២១ ទៅ ៣៥,៨លានដុល្លារនៅក្នុងឆ្នាំ ២០២២ ចំណែកឯចំនួនអតិថិជនបានកើនឡើង ២២% ដោយកើនពី ១.៨១២ គ្រួសារ ក្នុងឆ្នាំ ២០២១ ទៅ ២.១៧៩គ្រួសារ ក្នុងឆ្នាំ ២០២២ នេះ ។

ជាមួយបទពិសោធន៍ក្នុងវិស័យមីក្រូហិរញ្ញវត្ថុរយៈពេលជាច្រើនឆ្នាំ ហ្វីស ហ្វាយនែន បានពង្រីកវិសាលភាពប្រតិបត្តិការរបស់ខ្លួនបន្ថែមដោយបានបង្កើតការិយាល័យសាខា និងបង្កើនចំនួនបុគ្គលិកផ្នែកឥណទាននៅគ្រប់សាខា ដែលពីមុនមានត្រឹម ២៨ នាក់ ឡើងទៅ ១២១គិតត្រឹមបំណាច់ឆ្នាំ ២០២២ ។ ជាលទ្ធផលនៃការធ្វើឱ្យប្រសើរឡើងនេះ យើងខ្ញុំបានបញ្ចេញប្រាក់កម្ចីចំនួន ១៤,៦៧លានដុល្លាទៅកាន់អថិជន ៨២៥ គ្រួសារ ត្រឹមបំណាច់ឆ្នាំ ២០២២ ។



**១២១**
ចំនួនបុគ្គលិកឥណទាន



**៨២៥**
ចំនួនឥណទានដែលបានបញ្ចេញ

## ការពង្រឹងគុណភាព

ការគ្រប់គ្រងហានិភ័យត្រូវបានកំណត់ឡើងតាមការប្រភេទប្រតិបត្តិការ ដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យសន្ទនិយភាព ហានិភ័យប្រតិបត្តិការ និងហានិភ័យប្រតិបត្តិតាម ។ ការគ្រប់គ្រងហានិភ័យ ជាទូទៅគឺធ្វើឡើងដើម្បីធានាបាននូវស្ថេរភាពហិរញ្ញវត្ថុ និងជៀសផុតពីសកម្មភាពទាំងឡាយណា ដែលនាំឱ្យប៉ះពាល់ទៅដល់កេរ្តិ៍ឈ្មោះរបស់ ហ្វីស ហ្វាយនែន ។

សមាជិកគណៈកម្មការត្រូវបានតែងតាំងឡើងដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មការគ្រប់គ្រងហានិភ័យគប្បីមានសមាជិកយ៉ាងតិច៣នាក់។ ប្រធានគណៈកម្មការគប្បីជាសមាជិកនៃក្រុមប្រឹក្សាភិបាល ។ គណៈកម្មការគ្រប់គ្រងហានិភ័យ មានបទពិសោធន៍ទាក់ទងទៅនឹងហិរញ្ញ-វត្ថុ ធនាគារ និងគ្រប់គ្រងហានិភ័យ ។ សមាជិកគណៈកម្មការគ្រប់គ្រងហានិភ័យរួមមាន៖

1. លោក Hanco Halbertsma ប្រធាន
2. លោក អ៊ុំ សូផន សមាជិក
3. លោក ស៊ូ វណ្ណថន សមាជិក
4. លោក នាង សុខឃីម អ្នកអង្កេត

លទ្ធផល ដែលគណៈកម្មការគ្រប់គ្រងហានិភ័យសម្រេចបានក្នុងឆ្នាំ ២០២២ ៖

- ពង្រឹងកិច្ចការប្រតិបត្តិតាម ទាក់ទងទៅនឹងច្បាប់ និងបទបញ្ញត្តិ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា និងនិយ័តករផ្សេងទៀត ។
- បញ្ជៀបជាប្រចាំពីការគ្រប់គ្រងហានិភ័យឥណទានដោយជម្រុញឱ្យមានការអនុវត្តន៍ទៅតាមក្បួនខ្នាត និងការណែនាំដែលមាននៅក្នុងគោលនយោបាយ នីតិវិធី ឬសេចក្តីណែនាំរបស់ហ្វីស ហ្វាយនែន ។
- គ្រប់គ្រងការខូចខាតដែលអាចកើតឡើងទាំងបាន និងមិនបានគ្រោងទុក ព្រមជាមួយការទប់ស្កាត់ហានិភ័យ ដែលកើតឡើងពីការផ្តោតទៅលើវិស័យតែមួយ មកផ្តោតលើការធ្វើឱ្យមានភាពចម្រុះលើផលបត្រឥណទានដែលសមស្រប ។
- ពង្រឹងគុណភាពកម្ចី
- ត្រួតពិនិត្យគុណភាពកម្ចីជាប្រចាំខែ
- ពង្រឹងដំណើរការដោះស្រាយកម្ចីមិនដំណើរការ




បញ្ជៀបវប្បធម៌គ្រប់គ្រងហានិភ័យ



ពង្រឹងកិច្ចការប្រតិបត្តិតាម

## ទីផ្សារ និងប្រាស្រ័យទាក់ទង

ហ្វីស ហ្វាយនែន បានខិតខំផ្សព្វផ្សាយពីម៉ាកយីហោ និងសារទៅកាន់អតិថិជនគោលដៅរបស់ខ្លួន ដោយបញ្ជាក់ឱ្យបានដឹងថាការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនគឺជារឿងដែលធ្វើបាន និងអាចទៅរួច ដើម្បីឱ្យពួកគាត់មានឱកាសទទួលបានសុវត្ថិភាព ស្ថេរភាព និងទ្រព្យដែលមានតម្លៃ តាមរយៈការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន បើទោះបីគ្រួសារពួកគាត់មានចំណូលទាបក៏ដោយ ។ ព្រមជាមួយគ្នានេះដែរ អត្ថបទអប់រំខ្លីៗស្តីអំពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងសិទ្ធិគ្រប់គ្រងអចលនទ្រព្យក៏ត្រូវបានផ្សព្វផ្សាយនៅតាមបណ្តាញសង្គមរបស់យើងខ្ញុំផងដែរ ។



៥៩
អត្ថបទអប់រំខ្លីៗ ផ្សាយលើបណ្តាញសង្គម

## អាជីវកម្មស្វ័យប្រវត្តិ

នាយកដ្ឋានព័ត៌មានវិទ្យា បានផ្តល់នូវសេវាដែលចាំបាច់ទាក់ទងទៅនឹងប្រព័ន្ធព័ត៌មានសម្រាប់អ្នកគ្រប់គ្រង ថែទាំហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ពង្រឹងប្រព័ន្ធសុវត្ថិភាពព័ត៌មានវិទ្យា ធ្វើឱ្យប្រសើរឡើងលើការរក្សាទុកទិន្នន័យ និងរបាយការណ៍ B2B សម្រាប់ក្រេឌីតប៊ុយរ៉ូកម្ពុជា។ យើងបានធ្វើបច្ចុប្បន្នភាពទៅ Domain Name System (DNS) ដោយអនុលោមតាមបទបញ្ញត្តិនៃរាជរដ្ឋាភិបាល និងបានដាក់បញ្ចូលផលិតផលមួយចំនួនចូលទៅក្នុងប្រពន្ធ័ស្វ័លធនាគារ ។ ជាងនេះទៅទៀតនាយកដ្ឋានព័ត៌មានវិទ្យាបានបង្កើតនូវរបាយការណ៍មួយចំនួនក្នុងការជួយពន្លឿនប្រតិបត្តិការប្រចាំថ្ងៃ និងសម្រាប់ថ្នាក់គ្រប់គ្រងផងដែរ ។



ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មានវិទ្យា



បង្កើតរបាយការណ៍សម្រាប់អ្នកគ្រប់គ្រង


កម្ចីកែលម្អផ្ទះ
50,000 ដុល្លារ
រយៈពេលរហូតដល់ ១០ ឆ្នាំ
សម្រេចចិត្តលើកន្លែង
ដែលលោកអ្នកត្រូវកែលម្អ
រឿងថវិកា សូមពិភាក្សាជាមួយ ហ្វើស ហ្វាយនែន
093 666 635
firstfinance
www.firstfinance.com.kh
FIRST FINANCE

# ទិដ្ឋភាពទូទៅនៃសមិទ្ធិផលសង្គម និងបរិស្ថាន

ចាប់តាំងពីពេលដែលបានបង្កើតក្រុមការងារនៅក្នុងឆ្នាំ ២០១៩ មក ហ្វីស ហ្វាយនែន នៅតែបន្តការផ្តល់ប្រឹក្សាអំពីព័ត៌មានទូទៅបន្ថែមទាក់ទងទៅនឹងកម្ចីលំនៅដ្ឋានទៅកាន់សាធារណជន និងអតិថិជនរបស់ខ្លួន ដែលវាគឺជាផ្នែកនៃបេសកកម្មសង្គមក្នុងការផ្តល់សេវាមិនមែនហិរញ្ញវត្ថុ ។ សាធារណជនអាចទូរសព្ទសាកសួរអំពីដំណើរការក្នុងការកាត់ប្លង់ របៀបពិនិត្យមើលពីភាពស្របច្បាប់របស់អ្នកអភិវឌ្ឍអចលនទ្រព្យ និងបញ្ហាផ្សេងទៀតទាក់ទងទៅនឹងផ្ទះសម្បែង ។ ជាមួយគ្នានេះផងដែរ យើងខ្ញុំបានបង្កើតអត្ថបទអប់រំខ្លីៗ រួចដាក់បង្ហាញនៅលើបណ្តាញសង្គមហ្វេសប៊ុក ។ ក្នុងឆ្នាំ ២០២២ អត្ថបទខ្លីៗទាំងនោះមានប្រមាណជិត ៦០អត្ថបទ ត្រូវបានចែកចាយនៅលើបណ្តាញសង្គម ដែលអត្ថបទនីមួយៗបានទៅដល់អ្នកអានប្រមាណ ៥០០ នាក់ ។ ហ្វីស ហ្វាយនែន ពិតជាមានមោទកភាពដែលបានចូលរួមបង្កើននូវចំណេះដឹងបន្ថែមទៅកាន់សាធារណជន ដើម្បីឱ្យពួកគាត់អាចការពារខ្លួនឯងបាន និងធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ ក្នុងការជ្រើសរើសទិញអចលនទ្រព្យដែលជាលំនៅដ្ឋានរបស់ពួកគាត់ ។

ហ្វីស ហ្វាយនែន បានឈានមួយជំហានទៀត ក្នុងការគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថានប្រកបដោយប្រសិទ្ធិភាព តាមរយៈការបង្កើតគោលនយោបាយគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថាន ការបង្កើតក្របខណ្ឌហិរញ្ញវត្ថុសង្គម និងរបាយការណ៍ដែលវាត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយស្ថាប័នមួយឈ្មោះថា Moody’s ។ យើងខ្ញុំក៏បានផ្តល់ការអប់រំអំពីការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ព្រមជាមួយរបៀបនៃការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យទាំងនោះទៅកាន់បុគ្គលិក អតិថិជន និងសហគមន៍ ។ ហ្វីស ហ្វាយនែន បានដាក់បញ្ចូលការវាយតម្លៃពីផលប៉ះពាល់សង្គម និងបរិស្ថានចូលទៅក្នុងនីតិវិធីសិក្សាវាយតម្លៃឥណទាន ក៏ដូចជាដំណើរការពិនិត្យ និងតាមដានឥណទានក្នុងគោលបំណងការពារ និងកាត់បន្ថយគ្រោះថ្នាក់ដល់បរិស្ថាន និងចូលរួមលើកតម្កើងឱ្យមានសមភាព និងសមធម៌ក្នុងសង្គម ។ យើងខ្ញុំនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃឥណទានឡើងវិញជាប្រចាំឆ្នាំសម្រាប់កម្ចីដែលធំជាង ៣ម៉ឺនដុល្លារឡើង ។

## គោលការណ៍បរិស្ថាន និងសង្គម



តែងតែគិតគូរពីផលប៉ះពាល់សង្គម និងបរិស្ថាននៅគ្រប់សេចក្តីសម្រេចចិត្ត ដោយរួមបញ្ចូលការគ្រប់គ្រងធនធានមនុស្ស និងផលប៉ះពាល់ពីប្រតិបត្តិការ ហិរញ្ញប្បទាន និងលទ្ធកម្ម



អនុលោមតាមច្បាប់ទាំងឡាយទាក់ទងទៅនឹងបរិស្ថាន រួមមានបទបញ្ញត្តិរបស់ប្រទេសកម្ពុជា ច្បាប់អន្តរជាតិ និងការអនុវត្តន៍ផ្សេងៗ ដើម្បីធានានិរន្តរភាពប្រតិបត្តិការ កំណើនអតិថិជន និងកាត់បន្ថយហានិភ័យ



ធ្វើប្រតិបត្តិការដោយប្រុងប្រយ័ត្ន ដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ និងមានការត្រួតពិនិត្យយ៉ាងទៀងទាត់ ក្នុងការវាយតម្លៃ និងចាប់យកគោលការណ៍នោះមកអនុវត្តន៍ដើម្បីការពារ និងកាត់បន្ថយគ្រោះថ្នាក់ទៅដល់បរិស្ថាន ក៏ដូចជាលើកតម្កើងសមភាព និងសមធម៌សង្គម



ចូលរួមជាមួយភាគីពាក់ព័ន្ធ ក្នុងការគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន និងកំណត់ឱ្យបាននូវឱកាសដើម្បីធ្វើឱ្យមានភាពប្រសើរឡើង

គោលការណ៍របស់យើងខ្ញុំត្រូវបានបង្កើតឡើង ស្របទៅតាមការប្ដេជ្ញាចិត្តរបស់យើងខ្ញុំ ក៏ដូចជាស្របទៅនឹង គោលដៅអភិវឌ្ឍប្រកបដោយស្ថេរភាពរបស់អង្គការសហប្រជាជាតិ (UN SDGs)។ យើងខ្ញុំបានផ្ទួងគោលការណ៍របស់យើងទៅនឹង ១០ គោលដៅអភិវឌ្ឍប្រកបដោយស្ថេរភាពរបស់អង្គការសហប្រជាជាតិ អាស្រ័យតាមកិច្ចការដែលមានផលប៉ះពាល់ច្រើនជាងគេ




# សមិទ្ធផលបរិស្ថាន និងសង្គម

## សកម្មភាព និងអាជីវកម្មដែលមានស្ថេរភាព

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធផលឆ្នាំ ២០២២ |
|---|---|---|
|  | **ចំណេះដឹង និងបរិយាបន្នហិរញ្ញវត្ថុ**<br>ការផ្ដល់សេវាហិរញ្ញវត្ថុ ទៅកាន់គ្រួសារដែលមានចំណូលទាបនិងមធ្យម និងគ្រួសារដែលមានផ្ទះជាលើកដំបូង | • ៦២% នៃអតិថិជនមានចំណូលក្រោម ៧០០ ដុល្លារ ក្នុង ១ខែ<br>• ផ្ដល់សេវាហិរញ្ញវត្ថុទៅដល់ ២.១៧៩ គ្រួសារជាមួយផលបត្រឥណទាន ៣៥,៨ លានដុល្លារ<br>• ៦៤% នៃអតិថិជន គឺជាស្ត្រី<br>• ៦៣% នៃអតិថិជន គឺជាអ្នកដែលមានផ្ទះដំបូងក្នុងជីវិត<br>• អត្ថបទខ្លីៗ ចំនួន ៥៩ ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងចំណេះដឹងអំពីសិទ្ធិអចលនទ្រព្យត្រូវបានបង្កើតនឹងផ្សព្វផ្សាយលើបណ្ដាញសង្គម |
| | លទ្ធភាពទទួលបានសេវាកម្មលំនៅដ្ឋានខ្នាតតូច ទឹកស្អាត និងអនាម័យ | • ប្រហែល ៦០% នៃអតិថិជន បានប្រើប្រាស់សេវាកម្ម លំនៅដ្ឋានខ្នាតតូចដើម្បីកែប្រែគុណភាពជីវិតឱ្យបានប្រសើរឡើង |
| | **បទពិសោធន៍អតិថិជន**<br>ការឱ្យពិន្ទុទៅលើភាពពេញចិត្ត<br><br>កម្រិតនៃការថែរក្សាអតិថិជន | • ៧៥% នៃអតិថិជន ពេញចិត្តពីសេវាអតិថិជន<br><br>• កម្រិតថែរក្សារអតិថិជន ៧៧,៣% |
| | **ភាពចម្រុះ និងបរិយាបន្ន**<br>តួនាទីស្ត្រីនៅក្នុងជួរថ្នាក់ដឹកនាំ | • ១០% |
| | **បម្រែបម្រួលអាកាសធាតុ**<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់ | • បរិមាណប្រេងឥន្ធនៈ(លីត្រ)៖ ៤៤.៩៥៦<br>• បរិមាណភ្លើងអគ្គិសនី៖ ១៨៧.៤៩៩ |

## ទំនួលខុសត្រូវផ្នែកសង្គម

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធិផលឆ្នាំ ២០២២ |
|---|---|---|
| 4 QUALITY EDUCATION<br>13 CLIMATE ACTION | **ការតបស្នងទៅកាន់សហគមន៍**<br>ការអភិវឌ្ឍន៍ធនធានមនុស្ស | • អនុវត្តន៍គម្រោងបណ្ណាល័យចំនួន ៣ |

## អភិបាលកិច្ច និងហានិភ័យ

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធិផលឆ្នាំ ២០២២ |
|---|---|---|
| 10 REDUCED INEQUALITIES<br>12 RESPONSIBLE CONSUMPTION AND PRODUCTION<br>13 CLIMATE ACTION<br>16 PEACE, JUSTICE AND STRONG INSTITUTIONS | **អភិបាលកិច្ច និងក្រមសីលធម៌**<br>មានគោលនយោបាយត្រឹមត្រូវក្នុងការគាំទ្រទៅដល់សកម្មភាព និងអាជីវកម្មប្រកបដោយស្ថេរភាព<br><br>ត្រួតពិនិត្យ និងតាមដានកម្ចីដើម្បីធានាបានថាប្រភពចំណូលអតិថិជនមិនប៉ះពាល់ទៅដល់បរិស្ថាន និងសង្គម | • កែសម្រួលនីតិវិធីគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថាន<br>• បង្កើតគោលការណ៍ សុវត្ថិភាព និងសន្តិសុខ<br>• កែសម្រួលយន្តការណ៍ដោះស្រាយបណ្តឹង<br>• ដាក់បញ្ចូលបញ្ជីអាជីវកម្មដែលហាមឃាត់ចូលទៅក្នុងនីតិវិធីវាយតម្លៃ និងត្រួតពិនិត្យឥណទាន<br>• កែសម្រួលនីតិវិធីរាយការណ៍ជាសម្ងាត់<br>• កែសម្រួលក្រមសីលធម៌<br>• កែសម្រួលនីតិវិធី និងគោលនយោបាយឥណទាន<br>• បង្កើតនីតិវិធីគ្រប់គ្រងហានិភ័យឥណទាន<br>• កែសម្រួលនីតិវិធីប្រតិបត្តិតាម<br>• កែសម្រួលគោលនយោបាយធនធានមនុស្ស |
| | ស្ត្រីនៅក្នុងជួរក្រុមប្រឹក្សាភិបាល | • 0 |

## ចូលរួមជាមួយអ្នកពាក់ពន្ធ័ និងតស៊ូមតិ

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធិផលឆ្នាំ ២០២២ |
|---|---|---|
| 8 DECENT WORK AND ECONOMIC GROWTH<br>10 REDUCED INEQUALITIES | **ការទាក់ទាញ អភិវឌ្ឍ និងថែរក្សាបុគ្គលិក**<br>ចំនួនបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលលើការគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថាន | • ដោយគោលនយោបាយទើបតែបានបង្កើត ដូច្នេះការផ្តល់ជូនវគ្គបណ្តុះបណ្តាលនៅត្រូវធ្វើឡើងនៅដើមឆ្នាំ ២០២៣ ដោយដាក់បញ្ចូលទៅក្នុងកម្មវិធីតម្រង់ទិសសម្រាប់បុគ្គលិកថ្មី និងវគ្គរំលឹកឡើងវិញ ។ |

# ការទទួលស្គាល់កម្រិតខ្ពស់ក្នុងការអនុវត្តន៍គោលការណ៍ការពារអតិថិជន




ជាមួយបេសកកម្មសង្គមក្នុងការពង្រីកវិសាលភាព ផ្តល់សេវាកម្ចីលំនៅដ្ឋានខ្នាតតូចរយៈពេលវែងទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដើម្បីផ្តល់លទ្ធភាពឱ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន និងបានរស់នៅក្នុងជីវភាពមួយដែលមានស្ថេរភាព ហ្វឹស ហ្វាយនែន បានប្តេជ្ញាក្នុងការការពារមិនឱ្យមានបំណុលវណ្ឌក ការយកចិត្តខ្ពស់ ក៏ដូចជាការផ្តល់ជូននូវតម្លាភាពសម្រាប់គ្រប់អតិថិជនទាំងអស់ ។ ការទទួលបានវិញ្ញាបនបត្រកម្រិតខ្ពស់បំផុតពីស្ថាប័ន M-Cril នៅក្នុងឆ្នាំ ២០២២ បានបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ក្នុងការអនុវត្តន៍នូវគោលការណ៍ការពារអតថិជននៅក្នុងគ្រប់សកម្មភាពប្រតិបត្តិការប្រចាំថ្ងៃរបស់យើងខ្ញុំ ។ គោលការណ៍ទាំងនោះរួមមាន (១) ការបង្កើត និងផ្តល់ផលិតផលដែលសមរម្យ (២) ការការពារការជាប់បំណុលវណ្ឌក (៣) តម្លាភាព (៤) ការកំនត់តម្លៃដែលមានការទទួលខុសត្រូវ (៥) ការដោះស្រាយជាមួយអតិថិជនដោយគោរព និងយុត្តិធម៌ (៦) ការរក្សាព័ត៌មានសម្ងាត់របស់អតិថិជន (៧) យន្តការសម្រាប់ដោះស្រាយបណ្តឹង ឬការតវ៉ារបស់អតិថិជន ។

# របាយការណ៍របស់សវនករឯករាជ្យ

( ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២ និងរបាយការណ៍របស់សវនករឯករាជ្យ )

**ជូនចំពោះភាគហ៊ុនិកនៃ**

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី**

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងរបាយការណ៍ចំណូលលម្អិត

របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ព្រមទាំងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ព័ត៌មានផ្សេងទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវជាសារវន្តលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម (“CIFRS for SMEs”) រួមជាមួយនឹងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា (“NBC”)។

## មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែក ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយ-ការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ ) (“IESBA Code”) រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើ សវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវ ទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដែលទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលបានរំពឹងទុកថានឹងរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ ហើយយើងខ្ញុំមិនផ្តល់សេចក្តីសន្និ-ដ្ឋានក្នុងទម្រង់ពីការធានាបែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើផ្អែកតាមការងារដែលយើងខ្ញុំ ធ្វើសវនកម្មលើព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ យើងខ្ញុំសន្និដ្ឋានថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ ទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំនិងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយ អនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម រួមជាមួយនឹងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិ

ដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាងប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs") នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា("CISAs") យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏ៈ

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជា សារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនា ដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានដ៏សមស្របមួយ ទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំង ទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ទៅនឹងការលាតត្រដាងនៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅរចនាសម្ព័ន្ធនិងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

Grant Thornton

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០.៥៦២.១៩៩ | ៤៣.៤៨៤.៥៧៣ | ១.៩៥០.៤១២ | ៧.៩៤៥.៩៧៨ |
| ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ | ៧៥០.០០០ | ៣.០៨៧.៧៥០ | ១៨០.១០២ | ៧៣៣.៧៣៦ |
| ឥណទានផ្តល់ជូនអតិថិជន - សុទ្ធ | ៣៥.២៦៣.៨២៤ | ១៤៥.១៨១.១៦៣ | ៣០.២៨៩.២២៦ | ១២៣.៣៩៨.៣០៧ |
| ទ្រព្យសកម្មផ្សេងៗ | ៧២៥.៩៦៩ | ២.៩៨៨.៨១៤ | ៣៨២.៩៧៩ | ១.៥៦០.២៥៦ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៣៣៩.៧៤៤ | ១.៣៩៨.៧២៦ | ៩៦.១៩៥ | ៣៩១.៨៩៨ |
| ទ្រព្យសកម្មអរូបី | ៨.៦២៤ | ៣៥.៥០៥ | ៤១.១២៨ | ១៦៧.៥៥៥ |
| ទ្រព្យសកម្មពន្ធពន្យារ- សុទ្ធ | ៣០.២៧៨ | ១២៤.៦៥៥ | ២៩.៦២៣ | ១២០.៦៨៤ |
| **ទ្រព្យសកម្មសរុប** | **៤៧.៦៨០.៦៣៨** | **១៩៦.៣០១.១៨៦** | ៣២.៩៦៩.៦៦៥ | ១៣៤.៣១៨.៤១៤ |
| **មូលធន និងបំណុល** | | | | |
| **បំណុល** | | | | |
| បំណុលផ្សេងៗ | ៤.៨៣៨.០១៥ | ១៩.៩១៨.១០៨ | ៣.៩២៧.៣៦៦ | ១៦.០០០.០៨៩ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ១១២.៤២២ | ៤៦២.៨៤១ | ៤០.៨៧៦ | ១៦៦.៥២៩ |
| អត្ថប្រយោជន៍និយោជិត | ២៩.៧២០ | ១២២.៣៥៧ | ១១៣.៩១៤ | ៤៦៤.០៨៦ |
| ប្រាក់កម្ចី | ២៦.៩៥០.៦៨០ | ១១០.៩៥៥.៩៥០ | ២១.៧១៩.៧៥៦ | ៨៨.៤៨៦.២៨៦ |
| **បំណុលសរុប** | **៣១.៩៣០.៨៣៧** | **១៣១.៤៥៩.២៥៦** | ២៥.៨០១.៩១២ | ១០៥.១១៦.៩៩០ |
| **មូលធន** | | | | |
| ដើមទុន | ១៥.០០០.០០០ | ៦០.០០០.០០០ | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ |
| បុព្វលាភភាគហ៊ុន | - | - | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៦៥២.៩១១ | ២.៦៥០.៩៩២ | ៤១៨.៦៦២ | ១.៦៩៣.៦២០ |
| ចំណេញរក្សាទុក | ៩៦.៨៩០ | ៣៩៥.៩៨៩ | ២.២៦៧.៥៧៦ | ៩.១៦០.០៤១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | - | ១.៧៩៤.៩៤៩ | - | ៤២១.៧០៣ |
| **មូលធនសរុប** | **១៥.៧៤៩.៨០១** | **៦៤.៨៤១.៩៣០** | ៧.១៦៧.៧៥៣ | ២៩.២០១.៤២៤ |
| **មូលធន និងបំណុលសរុប** | **៤៧.៦៨០.៦៣៨** | **១៩៦.៣០១.១៨៦** | ៣២.៩៦៩.៦៦៥ | ១៣៤.៣១៨.៤១៤ |

# របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងទៀត

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | **៤.៦៨១.៧៧៣** | **១៩.១៣៤.៤០៦** | ៣.៧៣៧.៣២៤ | ១៥.២០៣.៤៣៤ |
| ចំណាយការប្រាក់ | **(១.៩២៥.១៣៦)** | **(៧.៨៦៨.០៣១)** | (១.៨១១.៧១៩) | (៧.៣៧០.០៧៣) |
| **ចំណូលការប្រាក់សុទ្ធ** | **២.៧៥៦.៦៣៧** | **១១.២៦៦.៣៧៥** | ១.៩២៥.៦០៥ | ៧.៨៣៣.៣៦១ |
| ចំណូលកម្រៃសេវា និងជើងសា | **៣៥៧.៦៨១** | **១.៤៦១.៨៤២** | ៤១៦.៩៦៨ | ១.៦៩៦.២២៦ |
| ចំណូលផ្សេងៗ | **២៤៨.៣៧៥** | **១.០១៥.១០៩** | ១៤២.៥៩១ | ៥៨០.០៦០ |
| **ចំណូលប្រតិបត្តិការសុទ្ធ** | **៣.៣៦២.៦៩៣** | **១៣.៧៤៣.៣២៦** | ២.៤៨៥.១៦៤ | ១០.១០៩.៦៤៧ |
| ឱនភាពខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ | **(៤៤៨.៣៤១)** | **(១.៨៣២.៣៧០)** | (៣៨១.៦៧៣) | (១.៥៥២.៦៤៦) |
| ចំណាយបុគ្គលិក | **(១.៣៣៧.២០១)** | **(៥.៤៦៥.១៤០)** | (១.១៧១.០៧៨) | (៤.៧៦៣.៩៤៥) |
| រំលស់លើទ្រព្យសកម្មរូបី និងអរូបី | **(១២៦.៦៩៨)** | **(៥១៧.៨១៥)** | (៩៩.៩០៩) | (៤០៦.៤៣០) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | **(៩៧៩.៥២២)** | **(៤.០០៣.៣០៦)** | (៦៦៤.៣២១) | (២.៧០២.៤៥៨) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | **៤៧០.៩៣១** | **១.៩២៤.៦៩៥** | ១៦៨.១៨៣ | ៦៨៤.១៦៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | **(១៣៩.៧៩៣)** | **(៥៧១.៣៣៤)** | (៧៩.៦៣៥) | (៣២៣.៩៥៥) |
| **ចំណេញក្នុងការិយបរិច្ឆេទសុទ្ធ** | **៣៣១.១៣៨** | **១.៣៥៣.៣៦១** | ៨៨.៥៤៨ | ៣៦០.២១៣ |
| **ចំណូលលម្អិតផ្សេងៗ/(ខាត) -** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **១.៣៧៣.២៤៦** | - | ២០៥.៨២៧ |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **៣៣១.១៣៨** | **២.៧២៦.៦០៧** | ៨៨.៥៤៨ | ៥៦៦.០៤០ |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៤១៨.៦៦៣ | ១.៦៩៣.៦២០ | ២.២៦៧.៥៧៦ | ៩.១៦០.០៤១ | ៤២១.៧០៣ | ៧.១៦៧.៧៥៣ | ២៩.២០១.៤២៤ |
| ការបន្ថែមដើមទុន | ៨.២៥០.៩០៩ | ៣៣.០០៣.៦៣៦ | - | - | - | - | - | - | - | ៨.២៥០.៩០៩ | ៣៣.០០៣.៦៣៦ |
| មូលធនកម្មនៃប្រាក់ចំណេញរក្សាទុក | ២.២៦៧.៥៧៦ | ៩.១៦០.០៤១ | - | - | - | - | (២.២៦៧.៥៧៦) | (៩.១៦០.០៤១) | - | - | - |
| មូលធនកម្មនៃបុព្វលាភភាគហ៊ុន | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | (៨៧៩.៤៨២) | (៣.៥១៧.៩២៨) | - | - | - | - | - | - | - |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | ៣៣១.១៣៨ | ១.៣៥៣.៣៦១ | - | ៣៣១.១៣៨ | ១.៣៥៣.៣៦១ |
| បម្រែបម្រួលទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ២៣៤.២៤៨ | ៩៥៧.៣៧២ | (២៣៤.២៤៨) | (៩៥៧.៣៧២) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៨៩.៧៣៧) | - | - | - | - | - | - | ១.៣៧៣.២៤៦ | - | ១.២៨៣.៥០៩ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១៥.០០០.០០០** | **៦០.០០០.០០០** | **-** | **-** | **៦៥២.៩១១** | **២.៦៥០.៩៩២** | **៩៦.៨៩០** | **៣៩៥.៩៨៩** | **១.៧៩៤.៩៤៩** | **១៥.៧៤៩.៨០១** | **៦៤.៨៤១.៩៣០** |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៣៤០.០១២ | ១.៣៧៣.៦៧២ | ២.២៥៧.៦៧៨ | ៩.១១៩.៧៧៦ | ២១៥.៨៧៦ | ៧.០៧៩.២០៥ | ២៨.៦៣៥.៣៨៤ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | ៨៨.៥៤៨ | ៣៦០.២១៣ | - | ៨៨.៥៤៨ | ៣៦០.២១៣ |
| បម្រែបម្រួលទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ៧៨.៦៥០ | ៣១៩.៩៤៨ | (៧៨.៦៥០) | (៣១៩.៩៤៨) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២០៥.៨២៧ | - | ២០៥.៨២៧ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៤១៨.៦៦២ | ១.៦៩៣.៦២០ | ២.២៦៧.៥៧៦ | ៩.១៦០.០៤១ | ៤២១.៧០៣ | ៧.១៦៧.៧៥៣ | ២៩.២០១.៤២៤ |

# របាយការណ៍លំហូរទឹកប្រាក់

| | សម្រាប់បំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់បំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនបង់ពន្ធ | **៤៧០.៩៣១** | **១.៩២៤.៦៩៥** | ១៦៨.១៨៣ | ៦៨៤.១៦៨ |
| **និយ័តកម្មសម្រាប់៖** | | | | |
| ចំណូលការប្រាក់សុទ្ធ | **(២.៧៥៦.៦៣៧)** | **(១១.២៦៦.៣៧៥)** | (១.៩២៥.៦០៥) | (៧.៨៣៣.៣៦១) |
| ឱនភាពទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ | **៤៤៧.៧២៧** | **១.៨២៩.៨៦០** | ៣៨១.៦៧៣ | ១.៥៥២.៦៤៦ |
| រំលស់ និងរំលស់ទ្រព្យសកម្មអរូបី | **១២៦.៣៩១** | **៥១៦.៥៦០** | ៩៩.៩០៩ | ៤០៦.៤៣០ |
| ការលុបចោលទ្រព្យសម្បត្តិ និងបរិក្ខារ | **-** | **-** | ១.២៩៥ | ៥.២៦៨ |
| ខាតបង់ពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | **១១.៤៤៥** | **៤៦.៧៧៦** | - | - |
| ឥណទានស្តារឡើងវិញ | **(១៦០.៥០៨)** | **(៦៥៥.៩៩៦)** | (២៣៦.៩៨៤) | (៩៦៤.០៥១) |
| **ខាតប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | **(១.៨៦០.៦៥១)** | **(៧.៦០៤.៤៨០)** | (១.៥១១.៥២៩) | (៦.១៤៨.៩០០) |
| **បម្រែបម្រួលសុទ្ធក្នុង៖** | | | | |
| ឥណទានផ្តល់ជូនអតិថិជន | **(៥.២៦១.៨១៧)** | **(២១.៥០៥.០៤៦)** | (៧.៤៩៩.៤១៦) | (៣០.៥០៧.៦២៤) |
| ទ្រព្យសកម្មផ្សេងៗ | **(៣៤២.៩៨៩)** | **(១.៤០១.៧៩៦)** | (៦៤.១៦៨) | (២៦១.០៣៥) |
| បំណុលផ្សេងៗ | **៩១០.៦៤៩** | **៣.៧២១.៨២២** | ៣.៣២៤.៩៤១ | ១៣.៥២៥.៨៦០ |
| **សាច់ប្រាក់បានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | **(៦.៥៥៤.៨០៨)** | **(២៦.៧៨៩.៥០០)** | (៥.៧៥០.១៧២) | (២៣.៣៩១.៦៩៩) |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | **(៥៦៩.៨៩៨)** | **(២.៣២៩.១៧៣)** | - | - |
| ការប្រាក់ទទួលបាន | **៤.៦៨១.៧៧៣** | **១៩.១៣៤.៤០៦** | ៣.៧៣៧.៣២៤ | ១៥.២០៣.៤៣៤ |
| ការប្រាក់ដែលបានបង់ | **(១.៩២៧.៣៦៤)** | **(៧.៨៧៧.១៣៧)** | (១.៦២៧.៨៧៨) | (៦.៦២២.២០៨) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | **(៦៨.៩០២)** | **(២៨១.៦០២)** | (៦០.៤២៦) | (២៤៥.៨១៣) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | **(៨៤.១៩៤)** | **(៣៤៤.១០១)** | (២៧.៥២៦) | (១១១.៩៧៦) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | **(៤.៥២៣.៣៩៣)** | **(១៨.៤៨៧.១០៧)** | (៣.៧២៨.៦៧៨) | (១៥.១៦៨.២៦២) |
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | **(៣៤៧.៧៨១)** | **(១.៤២១.៣៨១)** | (៣២.៩៧៦) | (១៣៤.១៤៦) |
| ការទិញទ្រព្យសកម្មអរូបី | **(១.១០០)** | **(៤.៤៩៦)** | (២.៤៧៥) | (១០.០៦៨) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | **(៣៤៨.៨៨១)** | **(១.៤២៥.៨៧៧)** | (៣៥.៤៥១) | (១៤៤.២១៤) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | |
| ការបន្ថែមដើមទុន | **៨.២៥០.៩០៩** | **៣៣.៧២១.៤៦៥** | - | - |
| ការទូទាត់សងប្រាក់កម្ចី | **(៧.០៣៨.៤២៩)** | **(២៨.៧៦៦.០៥៩)** | (៦.៦៨៧.២៨៧) | (២៧.២០៣.៨៨៤) |
| សាច់ប្រាក់ដែលបានមកពីប្រាក់កម្ចី | **១២.២៧១.៥៨១** | **៥០.១៥៣.៩៥២** | ១០.០៨៤.០៤៨ | ៤១.០២១.៩០៧ |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញវត្ថុ** | **១៣.៤៨៤.០៦១** | **៥៥.១០៩.៣៥៨** | ៣.៣៩៦.៧៦១ | ១៣.៨១៨.០២៣ |
| បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | **៨.៦១១.៧៨៧** | **៣៥.១៩៦.៣៧៤** | (៣៦៧.៣៦៨) | (១.៤៩៤.៤៥៣) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមការិយបរិច្ឆេទ | **១.៩៥០.៤១២** | **៧.៩៤៥.៩៧៨** | ២.៣១៧.៧៨០ | ៩.៣៧៥.៤២០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **៣៤២.២២១** | - | ៦៥.០១១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | **១០.៥៦២.១៩៩** | **៤៣.៤៨៤.៥៧៣** | ១.៩៥០.៤១២ | ៧.៩៤៥.៩៧៨ |

# ការិយាល័យកណ្តាល

អគារលេខ ២៩៥ ផ្លូវ ២៧១
សង្កាត់ ទួលទំពូង II ខណ្ឌចំការមន
រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+855) 93 666 635
info@firstfinance.com.kh
firstfinance
firstfinance plc
firstfinance.com.kh